# គ្រោះថ្នាក់រប់បារី

# أضرار التدخين

នេះជាអ៊ីស្លាម
សៀវភៅទី6

# កំរងសំនួរចំលើយ
# នៃសាស្ត្រាចារ្យអ៊ីស្លាម
# ស្តីអំពី

# ច្បាប់នៃការជក់បារី


រៀបរៀងដោយលោកសាស្ត្រាចារ្យៈ **អាលីអាប់ឌុលអាលអាត្តាស់តារី**

**នាយកអង្គការអេះលីអាល់គួរអាន និងស៊ុណ្ណះ**

ប្រែសំរួលជាខេមរភាសាដោយៈ

គណៈកម្មការបកប្រែ និងបោះពុម្ពសៀវភៅ

នៃសមាគមសំរបសំរួលសង្គមនៃប្រទេសគុយវែត

សហការជាមួយសមាគមសប្បុរសធម៌ដើម្បីអភិវឌ្ឍន៍កម្ពុជា




## អារម្ភកថា

មិត្តអ្នកអានជាទីមេត្រី! នេះជាសមិទ្ធផលថ្មីមួយទៀតដែលក្រុមយើងខ្ញុំបានរៀបចំជាខេមរៈភាសាគឺកំរងសំនួរចំលើយស្តីពីការជក់បារី ។

សុខភាពគឺជាបញ្ហាសំខាន់សំរាប់មនុស្សលោកទូទៅ ។ ប្រសិនបើសុខភាពមិនល្អរាល់កិច្ចការពិតជាជួបការលំបាកថែមទាំងត្រូវចំណាយថវិកា និងពេលវេលាយ៉ាងច្រើនដើម្បីសុខភាពនេះផងដែរ ។ ដោយយល់ឃើញថាបារីនិងគ្រឿងស្រវឹងផ្សេងៗ វានឹងបង្កអោយខូចសុខភាពថែមទាំងជាអំពើមួយដែលសង្គមអ៊ីស្លាមហាមឃាត់ និងសង្គមជាតិទូទាំងពិភពលោកមិនគាំទ្រក្នុងការប្រើប្រាស់វាផងនោះ ទើបក្រុមយើងខ្ញុំយកសៀវភៅតូចមួយរៀបរៀងដោយលោកសាស្ត្រាចារ្យ**អាលីអាប់ឌុលអាលអាត្តាស់តារី** ជានាយកអង្គការអេះលីអាល់គួរអាន និងស៊ុណ្ណះមកប្រែសំរួលជាខេមរៈភាសាដើម្បីងាយយល់នូវច្បាប់ពីបញ្ហាជក់បារី ។

យើងខ្ញុំសង្ឃឹមថាអត្ថបទនេះនឹងផ្តល់ផលប្រយោជន៍ល្អៗ និងមានសារៈសំខាន់ដល់បងប្អូនទាំងអស់គ្នា ។

សូមបួងសួងសុំពីអល់ឡោះសូមទ្រង់ចង្អុលបង្ហាញដល់ក្រុមយើងខ្ញុំ និងមិត្តអ្នកអានជួបតែអំពើសុចរិតពីលោកីយ៍រហូតដល់បរលោក ។

សូមអរគុណ

**មាតិការអត្ថបទ** **ទំព័រ**

សំនួរចំលើយរបស់លោកសាស្ត្រាចារ្យ ម៉ះមូដសីលតូត.......................០៤
ទស្សនះដែលនិយាយថា វាជាប្រការដែលច្បាប់ហាមឃាត់ឬជាប្រការមិនល្អ
គឺជាទស្សនះដ៏ខ្លាំង ...................................................................០៥
បារីបង្កអោយគ្រោះថ្នាក់ដល់សុខភាព និងទ្រព្យសម្បត្តិត្រូវបានគេដាក់
បំរាម.......................................................................................០៦
ការធ្វើសឡាហ៍នៅក្នុងចំការថ្នាំគឺត្រឹមត្រូវ......................................០៨
សំនួរចំលើយរបស់លោកសាស្ត្រាចារ្យ ទូរ៉ាហ្គីស៊ី................................០៨
សំនួរចំលើយរបស់លោកសាស្ត្រាចារ្យ អាប់ឌុលឡោះកូនមូហាំម៉ាត់ .....០៩
សំនួរចំលើយរបស់សាស្ត្រាចារ្យ ហាំម៉ាត់កូនលោកណាសៀរ..............១៤
សំនួរចំលើយរបស់លោកសាស្ត្រាចារ្យ អាហ្គើហ្គាទីន .........................១៥
សំនួរចំលើយរបស់លោកសស្ត្រាចារ្យ ខាលីដកូនអះម៉ាត់.....................១៦
ទស្សនះរបស់អ្នកប្រាជ្ញអ៊ីស្លាមមួយចំនួនផ្សេងទៀត..........................១៦
សំនួរចំលើយរបស់គណៈកម្មការច្បាប់នៃប្រទេសអេហ្ស៊ីប.................១៧
សំនួរចំលើយរបស់លោកសាស្ត្រាចារ្យ កូនលោកអូសៃមីន.................១៩
សំនួរចំលើយរបស់លោកសាស្ត្រាចារ្យមូហាំម៉ាត់កូនលោកអ៊ីប្រាហ៊ីម....២២
កំរងសំនួរចំលើយរបស់លោកសាស្ត្រាចារ្យ អាប់ឌុររ៉ស់ម៉ានអាស្សាក់ឌី.៣៣



## ១- សំនួរចំលើយរបស់លោកសាស្ត្រាចារ្យ ម៉ះមូដសីលតូត

**សំណួរៈ**តើការដាំដើមថ្នាំជក់ ការផលិតថ្នាំជក់និងការជក់បារីជាប្រការដែលច្បាប់អ៊ីស្លាមដាក់ថាជាប្រការហាមឃាត់ដែរឬទេ? ចុះបើសឡាហ៍នៅក្នុងចំការថ្នាំជក់ ឬនៅក្នុងឃ្លាំងថ្នាំជក់ នាំអោយខូចសឡាហ៍ដែរឬទេ?

**ចំលើយៈ** បណ្តាទស្សនះរបស់សាសនវិទូអ៊ីស្លាមចំពោះបញ្ហាថ្នាំជក់មានដូចតទៅ :

ជាការពិតណាស់ ថ្នាំជក់មិនត្រូវបានគេស្គាល់នៅក្នុងបណ្តាប្រទេសអ៊ីស្លាមឡើយ ទើបតែនៅដើមទសវត្សទី១១ម.ស បានន័យថា វាទើបតែប្រហែល៤ទសវត្សចុងក្រោយនេះប៉ុណ្ណោះ។ ក្នុងករណីនេះហើយដែលសាសនវិទូអ៊ីស្លាមសម័យមុនៗគ្មានទស្សនះអ្វីចំពោះបញ្ហាក្រឹត្យក្រមច្បាប់ថា តើវាត្រូវបានច្បាប់អ៊ីស្លាមចាត់ទុកថាជាប្រការហាឡាល់ (ប្រការដែលច្បាប់អនុញ្ញាត) ឬ ប្រការហារ៉ាំ(ប្រការដែលច្បាប់មិនអនុញ្ញាត)នោះទេ ។ ផ្ទុយទៅវិញបណ្តាសាសនវិទូអ៊ីស្លាមនាសម័យបច្ចុប្បន្ននេះទេដែលបានបញ្ចេញទស្សនះស្តីពីរឿងថ្នាំជក់នៅក្នុងច្បាប់អ៊ីស្លាម (នេះដោយសារតែថ្នាំជក់បង្កគ្រោះដល់សុខភាពមនុស្សលោក) តែពួកគេមិនទាន់មានទស្សនះឯកភាពគ្នា តែមួយចំពោះរបស់ថ្មី ដែលមិនត្រូវបានគេស្គាល់ពីវិធានច្បាប់ ក្នុងពេលដែលច្បាប់កំពុងបញ្ចុះនោះឡើយ ។ ក្នុងចំណោមសាសនវិទូអ៊ីស្លាមយល់ថាៈ វាមិនត្រូវបានច្បាប់ហាមឃាត់នោះទេ ដោយសារថាវាមិនមែនជាគ្រឿងស្រវឹងហើយវាមិននាំអោយអ្នកប្រើប្រាស់ស្រវឹងនោះទេ និងដោយសារថាវាមិនបង្កផល

អាក្រក់ដល់មនុស្សទូទៅដែលប្រើប្រាស់វាដែរ ។ ក្នុងរូបភាពបែបនេះគេត្រូវមើលទៅប្រភពដើមរបស់វាគឺហាឡាល់ (អាចប្រើប្រាស់បាន) ក៏ប៉ុន្តែវានឹងក្លាយជាចំណីហារ៉ាំ សំរាប់បុគ្គលណាហើយដែលទទួលផលប៉ះពាល់ពីសារធាតុរបស់វា ។

## ទស្សនៈដែលនិយាយថាខាជាប្រការដែលច្បាប់ហាមឃាត់ ឬជាប្រការមិនល្អ គឺជាទស្សនៈដ៏ខ្លាំង

ទស្សនៈមួយចំនួនផ្សេងទៀតបានបញ្ជាក់ថាវាជាប្រការដែលច្បាប់ហាមឃាត់ ឬជាប្រការដែលមិនល្អ (ម៉ាក្រូស) ដោយសារការសង្កេតមើល និងកត់សំគាល់នូវភាពជាក់ស្តែង អំពីការប៉ះពាល់ដល់សុខភាពធ្វើអោយសុខភាពអ្នកប្រើប្រាស់ធ្លាក់ខ្លួនទន់ខ្សោយ លែងឃ្លានចំណីអាហារប៉ះពាល់ផ្លូវដង្ហើមជាក់ស្តែងវាបង្កអោយមានជំងឺថ្លើម និងសួត ។ ក្នុងចំណោមមូលដ្ឋានគ្រឹះទូទៅរបស់អ៊ីស្លាមបានអោយដឹងថា: គេដាក់ថាហារ៉ាំលើអ្វីមួយគឺដើម្បីរក្សាគោលជំនឿវិចារណញាណទ្រព្យសម្បត្តិ ឬកិត្តិយសរបស់បុគ្គលនោះ ។

បើវត្ថុនោះវានាំផលប៉ះពាល់ធ្ងន់ធ្ងរ បំរាមនោះធ្ងន់ធ្ងរដែរតែបើវាមានផលប៉ះពាល់តិចក៏បំរាមនោះស្រាលដែរ ។ ត្រូវដឹងថាសាសនាអ៊ីស្លាមយកចិត្តទុកលើសុខភាពរាងកាយមិនទាបជាង ការយកចិត្តទុកដាក់លើវិចារញាណនិងលុយកាក់នោះឡើយ ។ ភាគច្រើនដែលសាសនាអ៊ីស្លាមបានដាក់ថាហារ៉ាំលើអ្វីដែលគេអនុញ្ញាតអោយធ្វើនោះគឺដោយសារប្រការនោះផ្តល់ប្រយោជន៍



តិចជាងអត្ថប្រយោជន៍ ។ មិនតែប៉ុណ្ណោះពួកយើងយល់ឃើញថា:គេបានដាក់ហារ៉ាំចំពោះអ៊ីហ្វើដ៏ត(ការគោរព) ចាំបាច់ណាមួយបើគេដឹងច្បាស់ថា វាពិតជានាំមកនូវការគ្រោះថ្នាក់ ឬនាំអោយកាន់តែមានគ្រោះថ្នាក់ទ្វេដងនោះ! ។

## បារីត្រូវបានគេដាក់ថាហារ៉ាំដោយសារខាបង្កគ្រោះថ្នាក់ដល់សុខភាព និងការចំណាយទ្រព្យសម្បត្តិឥតប្រយោជន៍

ពិតមែនថាបារីផលប៉ះពាល់របស់វាមិនដល់ថ្នាក់ស្រវឹង និងមិនបង្កអោយបាត់បង់ដល់វិចារណញាណមែន តែសារធាតុរបស់វាមានសញ្ញាគ្រោះថ្នាក់ដែលអ្នកប្រើប្រាស់ និងអ្នកមិនប្រើប្រាស់គេបានដឹងពីរឿងនេះដោយខ្លួនគេផ្ទាល់ ។ ពិតមែនថាវេជ្ជបណ្ឌិតមួយចំនួនដែលគេស្គាល់ថាមានចិត្តលំអៀងទៅរកភាពរីករាយរបស់មនុស្សបានបញ្ជាក់ថា វាមិនមែនជាប្រការដែលច្បាប់ហាមឃាត់នោះឡើយ ។ ដូចនេះវាបង្ហាញអោយឃើញថាបារីពិតជាបង្កគ្រោះថ្នាក់មែន ។ អ្វីក៏ដោយដែលបង្កគ្រោះថ្នាក់គឺពិតជាអាក្រក់ហើយប្រការអាក្រក់គឺត្រូវបានសាសនាអ៊ីស្លាមហាមឃាត់ជាដាច់ខាត ។ បើយើងសង្កេតមើលមួយជ្រុងទៀតឃើញថាបារីត្រូវចំណាយថវិកាជាច្រើន ហើយដែលថវិកាជាតំរូវការខ្លាំងណាស់របស់អ្នកជក់ គេអាចនិយាយមួយបែបទៀតថាគឺជាការចំណាយទៅលើរបស់ដែលគ្មានប្រយោជន៍ និងមិនល្អទាល់តែសោះ ។ ដូចនេះ បើយើងងាកមកមើលផ្នែកចំណាយលុយឥតប្រយោជន៍ គឺត្រូវបានច្បាប់សាសនាអ៊ីស្លាមហាមឃាត់ជាដាច់ខាតគឺមិនត្រូវបានអនុញ្ញាតឡើយ ។

ច្បាប់អ៊ីស្លាមកាលណាបង្ហាញនូវប្រការណាមួយកំណត់ថាៈជាប្រការដែលច្បាប់បានហាមឃាត់ ឬជាប្រការមិនល្អនោះ គឺមិនចាំបាច់ទាមទាអោយមានភស្តុតាងបញ្ជាក់លើវត្ថុ ឬប្រការនោះដាច់ដោយឡែកនោះទេ ។ ដោយហេតុផលរបស់ច្បាប់ឬមូលដ្ឋានគ្រឹះនៃច្បាប់ទូទៅ គឺតំលៃរបស់វាឈរលើការទទួលស្គាល់ច្បាប់ហើយបណ្តាហេតុផលឬគោលការណ៍ទាំងអស់ គឺសាសនាអ៊ីស្លាមមានជំហរយ៉ាងម៉ឺងម៉ាត់ នៅក្នុងការផ្តល់ជូនជាពតិមានអោយបានដឹងគ្រប់យ៉ាងទាំងអស់ដែលបានកើតមានដល់មនុស្សលោកថាវត្ថុនោះជាប្រការដែលច្បាប់អនុញ្ញាត ឬហាមឃាត់ ។ជាមួយគ្នានេះតាមរយៈការសិក្សាស្រាវជ្រាវវត្ថុនោះ និងសារជាតិរបស់វា បើកាលណាវាអាចបង្កអោយមានគ្រោះថ្នាក់ គឺត្រូវបានច្បាប់ហាមឃាត់ តែបើកាលណាវាមិនបង្កអោយមានគ្រោះអ្វីទេ គឺត្រូវបានច្បាប់អនុញ្ញាត និងបើកាលណាគុណប្រយោជន៍ និងគុណវិបត្តិស្មើគ្នាជាការប្រសើត្រូវគិតដល់ការការពារវាប្រសើជាងការព្យាបាល ។

## ភារកិច្ចរបស់ថ្នាក់ដឹកនាំ

ថ្នាក់ដឹកនាំមានតួនាទីសំខាន់បំផុតត្រូវយកចិត្តទុកដាក់ចំពោះសុខុមាលភាពពលរដ្ឋរបស់ខ្លួនដោយត្រូវទប់ស្កាត់រាល់ប្រការទាំងឡាយណាដែលអាចបង្កអោយមានគ្រោះថ្នាក់ ។ការទប់ស្កាត់គ្រោះថ្នាក់មិនអោយប៉ះពាល់ពលរដ្ឋរបស់ខ្លួនជាការចាំបាច់បំផុត ។

នេះគឺជាច្បាប់នៅក្នុងការពិសា ការដាំដុះ និងការផលិតបារី ។ បារីមិនបានផ្តល់ផលអ្វីក្រៅពីការពិសានោះឡើយ ។



## សឡាហ៏នៅក្នុងចំការថ្នាំគឺត្រឹមត្រូវ(គ្មានបញ្ហាអ្វីឡើយ)

គេត្រូវស្វែងយល់ថាៈ នៅក្នុងសាសនាអ៊ីស្លាមមិនជាប់ទាក់ទងគ្នារវាងការហាមឃាត់ពីការពិសាអ្វីមួយឬអំពើឥតផលប្រយោជន៍ និងរវាងភាពកខ្វក់របស់វានោះទេ ពោលគឺត្រូវដឹងថាមានវត្ថុដែលច្បាប់ហាមឃាត់ជាច្រើន តែវាជាវត្ថុជ្រះស្អាតដែលមិននាំអោយខូចសឡាហ៏ត្រង់កន្លែងវានោះទេ ដូចគ្នាដែរ សឡាហ៏នៅក្នុងចំការថ្នាំជក់ ឬរោងចក្រផលិត ជាការត្រឹមត្រូវមិននាំអោយខូច ឬឥតប្រយោជន៍នោះទេ ។

## ២- សំនួរចំលើយរបស់លោកសាស្ត្រាចារ្យទួរ៉ាហ្គីស៊ី

លោកបណ្ឌិតមូហាំម៉ាត់អាត់ទួរ៉ាហ្គីស៊ីអាល់ហាឡាហ្គីអាល់ម៉ាលីគីបានបញ្ជាក់ក្រោយពីការអត្ថាធិប្បាយដ៏វែងរបស់លោកពីអ្វីដែលពាក់ព័ន្ធនឹងបារីៈជារួមវាបានបង្ហាញថាបារីស្ថិតក្នុងចំណោមគ្រឿងញៀនដែលច្បាប់បានហាមឃាត់ក្នុងការប្រើប្រាស់ វាមានផលប៉ះពាល់ដល់សុខភាពយ៉ាងពិតប្រាកដ ។ អ្វីដែលនាំអោយខូចសុខភាព ត្រូវបានច្បាប់ហាមឃាត់ដោយមតិឯកភាពរបស់សាសនវិទូអ៊ីស្លាម និងដោយសារផលប៉ះពាល់របស់វាមានទំធំទើបសាសនាអ៊ីស្លាមហាមឃាត់ដូចដែលច្បាប់ហាមឃាត់ចំពោះគ្រឿងក្រអូបបើវាមានផលប៉ះពាល់នោះ ។

លោកវេជ្ជបណ្ឌិតបកស្រាយថាៈ តាមរយៈភស្តុតាង គឺច្បាប់បានហាមឃាត់ ទាំងការជក់និងការលក់ ពោលគឺរាល់អ្វីដែលគេហាមលក់គឺគេ

ហាមជក់ និងហាមទិញវាដែរ ដោយហេតុថាបើច្បាប់ហាមលក់គឺហាមទិញដែរ ។ ករណីខាងលើដែលបានបង្ហាញនូវសំនួរចំលើយអំពីមាគិារបស់អ៊ីម៉ាំម៉ាលិក និងមាគិាអ៊ីមាំហាណាហ្វី និងយោងលើការបំភ្លឺរបស់សាសនវិទូផ្សេងៗដែរ ។

## ៣- សំនួរចំលើយរបស់លោកសាស្ត្រាចារ្យអាប់ឌុលឡោះគូនមូហាំម៉ាត់

គេបានសួរលោកអាប់ឌុលឡោះ កូនមូហាំម៉ាត់នូវច្បាប់ដែលពាក់ព័ន្ធនឹងការជក់បារីដែលមនុស្សភាគច្រើននិយមពិសាវានោះ? ខណៈនោះលោកបានបកស្រាយថាៈវាមិនត្រូវសង្ស័យនោះទេព្រោះអល់ឡោះជ្រើសរើសនិងបញ្ជូនសាហាវីមូហាំម៉ាត់មកប្រកបដោយវាចាខ្លី តែបង្កប់នូវអត្ថន័យទូលំទូលាយបំផុត ។ វាជាឧត្តមភាពរបស់មូហាំម៉ាត់ដែលអល់ឡោះបានប្រទានពិសេសក្នុងចំណោមបណ្តាសាហាវីរបស់ទ្រង់ទាំងអស់ ។ ដូចដែលរ៉ស៊ូលុលឡោះបានមានប្រសាសន៏ក្នុងការបង្ហាញនូវពាក្យឧត្តមភាពរបស់លោកថាៈ **(وأُتيت جوامع الكَلِم)**មានន័យថាៈគេ(អល់ឡោះ)បានប្រទានអោយខ្ញុំនូវវាចាខ្លី តែបង្កប់នូវអត្ថន័យទូលំទូលាយបំផុត ។ បានន័យថាវាគ្រាន់តែប្រសាសន៏បន្តិចបន្តួចរបស់លោក តែវាបានបង្កប់នូវក្រឹត្យច្បាប់យ៉ាងពេញលេញដែលយើងមិនអាចនឹកស្មានដល់ ។ ដូចជាប្រសាសន៏របស់លោកថាៈ **(كُلّ مسكر حرام)** មានន័យថាៈរាល់គ្រឿងស្រវឹងគឺហារ៉ាំ (បំរាមដាច់ខាត) ប្រសាសន៏នេះវាចូលទាំងអស់នៃគ្រឿងស្រវឹង ។ រាល់សារធាតុដែលនាំអោយស្រវឹងធ្វើអោយបាត់បង់ស្មារតីជាចំណីអាហារ និងជាគ្រឿងផឹកដែល



មាននៅក្នុងសម័យរបស់ណាហ្គីក្តី និងសម័យក្រោយៗពីលោករហូតដល់ថ្ងៃបរលោកដូចដែលមានបញ្ជាក់នៅក្នុងហាហ្ទីស្ស[១] ជាច្រើនពីសាហាវីមូហាំម៉ាត់នូវការដាក់បំរាមពីការបរិភោគគ្រឿងស្រវឹងដូចជាស្រាជាដើម ដែលវាជាសារធាតុបង្កអោយបាត់បង់ស្មារតីនិងវិចារណញ្ញាណ ។ អំពីកូនលោកអ៊ូម៉ើរបញ្ជាក់ថាណាហ្គី[២] បានមានប្រសាសន៏ថាៈ **(كُلّ مسكر خمر وكُلّ خمر حرام)** មានន័យថាៈ រាល់អ្វីៗដែលស្រវឹងគឺចាត់ទុកថាជាសុរា ហើយរាល់សុរាទាំងអស់គឺត្រូវបានច្បាប់ហាមឃាត់ ។ នៅក្នុងសេចក្តីរាយការណ៏របស់អ៊ីម៉ាំមូស្លីមថាៈ **(كُلّ مسكر حرام)**មានន័យថាៈ រាល់គ្រឿងស្រវឹង គឺហារ៉ាំ (បំរាមដាច់ខាត) ។ អំពីលោកស្រីអាអ៊ីស្ហះបានពោលថាៈជាការពិតណាស់គេបានសួររ៉ស៊ូលុលឡោះអំពីការពិសារគ្រឿងស្រវឹង? ខណៈនោះលោកបានមានប្រសាសន៏ថាៈ រាល់គ្រឿងផឹកដែលបង្កអោយស្រវឹងគឺត្រូវបានច្បាប់ហាមឃាត់ ។ នៅក្នុងសេចក្តីរាយការណ៏របស់អ៊ីម៉ាំមូស្លីមបានបញ្ជាក់ថាៈរាល់គ្រឿងផឹកដែលស្រវឹង គឺត្រូវបានច្បាប់ហាមឃាត់ ។ កូនអាប់ឌុលហ្គើរបានអោយដឹងថាៈ បណ្តាអ្នកមានវិជ្ជាខាងផ្នែកច្បាប់អ៊ីស្លាមបានឯកភាពគ្នាថាហាហ្ទីស្សខាងលើសុទ្ធតែជាហាហ្ទីស្សដែលត្រឹមត្រូវ ។ ជាការពិតណាស់វត្ថុដែលច្បាប់បានដាក់កំណត់អំពីការបំរាមនោះ គឺសារធាតុដែលបង្កអោយស្រវឹង(ពុល)វាបានបង្ហាញយ៉ាងច្បាស់នូវការហាមឃាត់ ទោះបីវាតិចក៏ដោយ

---

១ - ពាក្យសំដី ទង្វើ និងការឯកភាពរបស់សាហាវីមូហាំម៉ាត់ ។

២ - សាហាវីមូហាំម៉ាត់ ។

បើប្រើច្រើនវានាំអោយស្រវឹងនោះ!។ អ្នកត្រូវដឹងថា! ពិតណាស់គ្រឿងស្រវឹងដែលនាំអោយបាត់បង់ស្មារតី និងវិចារណញ្ញាណមានពីរប្រភេទ :

**ប្រភេទទី១:** អ្វីដែលមានរសជាតិឆ្ងាញ់និងចំណូលចិត្ត។ បណ្ដាសាសនវិទូអ៊ិស្លាមបានបង្ហាញថា ទោះបីសារធាតុដែលបង្កអោយស្រវឹងមានលក្ខណៈរឹងឬរាវក៏ដោយ ហើយទោះបីវាជាចំណីអាហារសំរាប់ទទួលទានឬជាគ្រឿងផឹកក៏ដោយ និងបើទោះបីវាជាគ្រាប់ធញ្ញជាតិ ឬផ្លែល្មើឬទឹកដោះ(ទឹកដោះគោ - ពពែ)ឬផ្សេងពីនេះ។ គេបានរាប់បញ្ចូលនៅក្នុងបញ្ហានោះដែរ មានដូចជាដើមកញ្ឆាដែលគេយកមកលាយបញ្ចូលជាមួយទំពាំងបាយជូរ ឬផ្សេងពីនេះទៀតសំរាប់ជាគ្រឿងបរិភោគដើម្បីរសជាតិឆ្ងាញ់ និងការស្រវឹង។

**ប្រភេទទី២ :** សារធាតុអ្វីដែលបំផ្លាញវិចារណញ្ញាណនិងស្មារតីហើយវាមានសារជាតិស្រវឹងដែលពុំមានរសជាតិឆ្ងាញ់ក្ដី ឬមិនឆ្ងាញ់ក្ដី។ បណ្ដាសាសនវិទូអ៊ិស្លាមភាគច្រើនយល់ឃើញថា ត្រូវបានគេហាមឃាត់អ្វីដែលបង្កអោយស្រវឹងឬពុលខណៈពេលគេបរិភោគវាច្រើននោះ ។ពួកគេយល់ឃើញចំពោះខ្ចាតផឹកអ្វីដែលធ្វើអោយគេស្រវឹងនោះ ដោយសារការពិសារច្រើនទោះបីគេគិតថាវាជាវត្ថុដែលច្បាប់បានអនុញ្ញាតដោយការដោះសារ របស់គេក៏ដោយនេះជាទស្សនៈរបស់អ៊ិមុាំសើហ្វីអ៊ិនិងអ៊ិមុាំអះម៉ាត់។

**លោក អាប់ឌុលឡោះកូនមូហាំម៉ាត់ក៏បានពោលថា :** ការពាក់ព័ន្ធទៅនឹងអ្វីដែលយើងបានលើកមកតាមរយៈប្រសាសន៍របស់រ៉ស៊ូលុលឡោះ និងបណ្ដាទស្សនៈរបស់សាសនវិទូអ៊ិស្លាម បង្ហាញអោយឃើញថា: ថ្នាំជក់ដែលភាគ



ច្រើននៅពេលបច្ចុប្បន្នកំពុងប្រើប្រាស់វានោះត្រូវបានច្បាប់ហាមឃាត់។ វាក៏បានបង្ហាញថាអាចឈានដល់កំរិតស្រវឹងពេលណាគេប្រើប្រាស់ច្រើន ឬពេលណាដែលអ្នកប្រើប្រាស់បោះបង់វាមួយថ្ងៃឬពីរថ្ងៃមិនជក់ ក្រោយមកគេចាប់ជក់ឡើងវិញ។ ជាការពិតណាស់វាជាសារធាតុធ្វើអោយស្រវឹងនិងបំផ្លាញស្មារតី រហូតពេលខ្លះអ្នកប្រើប្រាស់វានិយាយជាមួយអ្នកដ៏ទៃដោយគេមិនដឹងខ្លួនថាកំពុងនិយាយអ្វីនោះទេ។ ពួកយើងសុំពីអល់ឡោះបញ្ចៀសទំលាប់ដែលមិនគប្បីនេះផង បើចំពោះអ្នកមានជំនឿលើអល់ឡោះ មានជំនឿលើរ៉ស៊ូលរបស់ទ្រង់ និងមានជំនឿនឹងថ្ងៃបរលោក មិនត្រូវជ្រើសយកទស្សនៈរបស់បុគ្គលណាម្នាក់មកអនុវត្ត នៅពេលបន្ទូលរបស់អល់ឡោះ និងប្រសាសន៍របស់រ៉ស៊ូលុលឡោះបានបញ្ជាក់ច្បាស់ហើយនោះទេ ពីព្រោះថាការប្ដេជ្ញាចិត្តទទួលស្គាល់មូហាំម៉ាត់ជាខ្ញុំបំរើ និងជារ៉ស៊ូលរបស់អល់ឡោះនោះ គឺត្រូវតែប្រតិបត្តិតាមលោកនូវអ្វីដែលលោកបង្គាប់ប្រើនិងត្រូវជៀសវាងពីអ្វីដែលលោកបានហាមឃាត់ និងត្រូវជឿជាក់នូវអ្វីដែលលោកបាននាំមក។ គេមិនទាន់ចាត់ទុកថាគោរពសក្ការៈចំពោះអល់ឡោះនោះទេ លើកលែងតែការគោរពនោះត្រឹមត្រូវតាមច្បាប់ ហើយចាំបាច់ត្រូវជ្រើសយកការបង្គាប់បញ្ជារបស់ទ្រង់មកអនុវត្ត មិនត្រូវងាកទៅរកទស្សនៈបុគ្គលណាម្នាក់ឡើយ។

**លោកបានពោលទៀតថា:** ចំពោះជនសេពគ្រឿងស្រវឹង ក្រោយពីគេបានដឹងពីការហាមឃាត់ហើយនោះ បុគ្គលនោះត្រូវទទួលពិន័យចំនួន៨០រំពាត់

ផ្ទុយទៅវិញ បើគេពិសាវាដោយគេមិនដឹងថាច្បាប់បានហាមឃាត់នោះទេ គឺបុគ្គលនោះមិនត្រូវទទួលការពិន័យឡើយ តែគេត្រូវបង្គាប់ប្រើបុគ្គលនោះអោយសារភាពនិងសុំការអភ័យទោសពីអល់ឡោះ ។បើទោះជាមានសាសនវិទូមួយចំនួនមានទស្សនៈថា: ថ្នាំជក់មិនត្រូវបានគេហាមឃាត់ និងមិនត្រូវបានគេអនុញ្ញាតអោយដែរ ។ នេះជាពាក្យសំដីអវិជ្ជាព្រោះអ្នកនិយាយមិនដឹងថាខ្លួនកំពុងនិយាយអំពីអ្វីនោះផងដូចនេះគេមិនត្រូវងាកទៅរកទស្សនៈនេះឡើយ ព្រោះប្រសាសន៍របស់សាហាវីមូហាំម៉ាត់ បានបញ្ជាក់ថា:

**(كُل مسكر حرام)** មានន័យថា:រាល់គ្រឿងស្រវឹងគឺហារ៉ាំ( បំរាមដាច់ខាត ) ។

លោកមានប្រសាសន៏ផងដែរថា:

**(وما أسكر كثيره حرم قَليلُه)**

មានន័យថា: អ្វីក៏ដោយ បើកាលណាច្រើនធ្វើអោយស្រវឹងនោះ ទោះតិចក៏ច្បាប់ហាមឃាត់ដែរ ” ។

**លោកបានឆ្លើយទៀតថា :** បើមានសាក្សី២នាក់អះអាងលើការធុំក្លិនបារីពីមាត់បុរសណាម្នាក់ គឺបុរសនោះត្រូវទទួលការដាក់ពិន័យចំនួន៨០រំពាត់ ។

**លោកបានឆ្លើយដែរថា :** ដោយឡែកអ្នកជក់បារី កាលណាសាក្សីពីរនាក់បានឃើញរូបគេកំពុងប្រព្រឹត្តនោះ ចាំបាច់ត្រូវយកគេទៅធ្វើការពិន័យចំនួន៤០រំពាត់ ។

**លោកបានឆ្លើយទៀតថា :** អ្នកជក់បារីត្រូវទទួលការពិន័យចំនួន៤០រំពាត់ តែបើគេមិនរាងចាលទេ ចាំបាច់ត្រូវពិន័យគេចំនួន៨០រំពាត់ ។



**លោកពោលទៀតថា :** បុគ្គលណាដាំថ្នាំជក់ ឬគេរកឃើញថ្នាំនៅក្នុងផ្ទះរបស់គាត់ ឬនៅជាមួយសំភារៈរបស់គាត់ ឬគាត់ប្រើប្រាស់វាតែម្តង គឺគាត់ត្រូវទទួលទណ្ឌកម្ម ។

**លោកពោលទៀតថា:** បើមានសាក្សី២នាក់អះអាងលើការធុំក្លិនបារីពីមាត់បុរសណាម្នាក់ គឺបុរសនោះត្រូវទទួលទណ្ឌកម្ម ពីព្រោះមិត្តសំលាញ់របស់សាហាវីមូហាំម៉ាត់បានដាក់ទណ្ឌកម្មលើបុគ្គលណាដែលគេរកឃើញថាមានក្លិនសុរាចេញពីមាត់របស់គេ ពីព្រោះសុរាជាគ្រឿងស្រវឹង ហើយរាល់គ្រឿងស្រវឹងគេហៅថាសុរា ។

## ៨- សំនួរចំលើយរបស់សាស្ត្រាចារ្យហាំម៉ាត់ត្វូនលោតណាសៀរ

គេបានសួរលោកពីច្បាប់រឿងថ្នាំជក់? លោកឆ្លើយថា: វាត្រូវបានច្បាប់ហាមឃាត់ ។ ដោយយោងតាមប្រសាសន៏របស់សាហាវីមូហាំម៉ាត់ថា:

**(كُل مسكر حرام)** មានន័យថា: រាល់គ្រឿងស្រវឹងគឺហារ៉ាំ( បំរាមដាច់ខាត់) ។

នៅក្នុងសេចក្តីរាយការណ៏ផ្សេងទៀតលោកមានប្រសាសន៏ថា:

**(ما أسكر كثيره فَملْئُ الكَف منه حرام)**

មានន័យថា: ”អ្វីក៏ដោយបើកាលណាច្រើនធ្វើអោយស្រវឹងឬពុលនោះ គឺចំនួនមួយទូកដៃនៃសារធាតុនោះ គឺត្រូវបានច្បាប់ហាមឃាត់ ”។ នេះគឺជាលក្ខណៈទូទៅចំពោះសារធាតុដែលបង្កអោយស្រវឹងទាំងអស់ ពីព្រោះណាហ្គីត្រូវបានគេផ្តល់នូវពាក្យខ្លីដែលមានន័យគ្រប់ជ្រុងជ្រោយហើយ សាសនវិទូ

អ៊ិស្លាមក៏បានទទួលយកការពិតនោះដែរ ។ គេបានសួរលោកទៀតអំពីច្បាប់ចំពោះការពិសាគ្រឿងស្រវឹង?

**លោកបានឆ្លើយថា :** រីឯការពិសាគ្រឿងស្រវឹងត្រូវដាក់ពិន័យចំនួន៤០រំពាត់ ។

## ៥- មតិបកស្រាយរបស់លោកសាស្ត្រាចារ្យ អាហ្មើតហ្គាទីន

គេបានសួរលោកអាប់ឌុលឡោះអាហ្មើតហ្គាទីនពីរឿងថ្នាំជក់?

លោកបានឆ្លើយថា: អ្វីដែលយើងយល់ឃើញគឺវាត្រូវបានច្បាប់ហាមឃាត់ដោយមានមូលហេតុពីរយ៉ាង :

**ទីមួយ:** ទទួលរងនូវការវិលវល់ក្នុងពេលគេមិនជក់វាមួយរយៈ បើក្រោយមកគេជក់វានោះ ឬវាអាចធ្ងន់ធ្ងរជាងនេះទៅទៀត បើវាមិនក៏រិតស្រវឹងទេក៏អាចថាធ្វើអោយអ្នកប្រើប្រាស់ និយាយផ្តេសផ្តាសដោយមិនដឹងខ្លួន ។ មានហាហ្ទីស្សមួយរាយការណ៏ដោយអ៊ីម៉ាំអះម៉ាត់ថា: សាហាវីមូហាំម៉ាត់បានហាមឃាត់រាល់សារធាតុទាំងឡាយណាដែលធ្វើអោយស្រវឹងនិងធ្វើអោយអ្នកប្រើប្រាស់និយាយផ្តេសផ្តាស ។

**ទីពីរ** :វាជាអាហារមិនល្អបង្កអោយមានមេរោគច្រើនបំផ្លាញដល់សុខភាព ។ សាសនវិទូអ៊ិស្លាមបានទាញយកភស្តុតាង មកបញ្ជាក់ពីការហាមឃាត់តាមរយៈបន្ទូលរបស់អល់ឡោះនៅជំពូកអាល់អាក់រ៉ហ្វ វាក្យខ័ណ្ឌ១៥៧ថា:

**(ويحل لهم الطيبات ويحرم عليهم الخبائث)**

មានន័យថា: "ហើយទ្រង់បានអនុញ្ញាតដល់ពួកគេអោយបរិភោគនូវចំណី



អាហារល្អៗ និងទ្រង់បានដាក់បំរាមលើពួកគេនូវចំណីអាហារទាំងឡាយណាដែលអាក្រក់ " ។ ចំណែកឯអ្នកដែលចូលចិត្ត គឺគេមើលមិនឃើញថាវាជាចំណីអាហារអាក្រក់នោះទេគឺវាមិនខុសពី.....មើលមិនឃើញពីគំរង់ឡើយ ។

## ៦- មតិបកស្រាយរបស់លោកសាស្ត្រាចារ្យខាលីដកូនអះម៉ាត់

លោកខាលីដកូនអះម៉ាត់បានឆ្លើយអំពីច្បាប់ តាមមាគ៌ាអ៊ីម៉ាំម៉ាលិកដោយលោកបានពោលថា: មិនត្រូវអនុញ្ញាតអោយអ្នកជក់បារីធ្វើអ៊ីម៉ាំសឡាហ៏ មិនត្រូវអនុញ្ញាតអោយធ្វើការជួញដូរថ្នាំជក់ និងមិនត្រូវអនុញ្ញាតអោយប្រើប្រាស់នូវសារធាតុទាំងឡាយណាដែលនាំអោយស្រវឹងឬពុលនោះឡើយ ។

## ៧- ទស្សនៈរបស់អ្នកប្រាជ្ញអ៊ិស្លាមមួយចំនួនផ្សេងទៀត

អ្នកអះអាងថា: ការជក់បារីត្រូវបានច្បាប់ហាមឃាត់ក្នុងចំណោមសាសនវិទូអ៊ិស្លាមនៅប្រទេសអេហ្ស៊ីប គឺលោកអះម៉ាត់អាល់សាន់ហ៊ូរី អាល់បាហ៊ូទី (ក្នុងមាគ៌ាអ៊ីម៉ាំអះម៉ាត់) លោកសាស្ត្រាចារ្យក្នុងមាគ៌ាម៉ាលីគី អាល់លីក៏នីនិងបណ្តាទស្សនៈវិទូនៅឯឌីមីសក៏អាន់ណាច់មុលហ្គាស្ស៊ី អាល់អាមីរីអាល់សើហ្វីអ៊ី និងបណ្តាសាសនវិទូនៅឯប្រទេសយេម៉ែន គឺលោកអ៊ីប៉រហ៊ីម កូនជាំអាន ។ ជាមួយនេះដែរសាសនវិទូអ៊ិស្លាមជាច្រើននៅសម័យបច្ចុប្បន្ននៅឯប្រទេសអារ៉ាប៊ីសាអ៊ូឌីតដូចជា លោកអាប់ឌុរ៉ស់ម៉ានណាសៀរអាល់សាក់ឌីលោកមូហាំម៉ាត់កូនអ៊ីប៉រហ៊ីម លោកអាប់ឌុលអាហ្ស៊ីសកូនហ្គើស លោក

អាប់ឌុលឡោះកូនមូហាំម៉ាត់កូនហាម៉េត និងមានសាសនវិទូអ៊ីស្លាមជាច្រើនទៀត តែយើងសូមលើកយកចំនួនប៉ុននេះវាគ្រប់គ្រាន់ហើយ ។ បើមានអ្នកមានបំណងចង់យល់ដឹងបន្ថែមពីបញ្ហានេះសូមសួរបន្ថែមទៀតចុះតែខ្ញុំគិតថាបើជាអ្នកមានសតិបញ្ញាញាណវិញ គឺពិតជានឹងមិនបកស្រាយថាៈ ការប្រើប្រាស់បារីជាប្រការស្របច្បាប់ឡើយ ព្រោះគេបានដឹងហើយពីផលប៉ះពាល់របស់វា ដល់ផ្លូវសាសនា សេដ្ឋកិច្ចសហគមន៍ កិរិយាមាយាទនិងដល់សុខភាពហើយខ្ញុំក៏មិនមានការមន្ទិលសង្ស័យអ្វីចំពោះអ្នកមានសតិបញ្ញាដែលគេបានលះបង់បារីមិនមែនត្រឹមតែពាក្យថា បំរាមនោះទេលុះត្រាគេធ្លាប់ភ្លក្សហើយដឹងពីផលប៉ះពាល់របស់វាមិនខានឡើយ ។

ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាជួយការពារនិងរារាំងពួកយើងពីបណ្តាអំពើបាបកម្មទាំងឡាយផងចុះ ហើយសូមទ្រង់ផ្តល់សុវត្ថិភាពដល់ពួកយើងនិងបណ្តាមូស្លីមទាំងឡាយតាមរយៈការបង្ហាញផ្លូវឆ្ពោះទៅរកអំពើល្អ និងកិច្ចប្រតិបត្តិទៅតាមគន្លងមាគ៌ាដ៏ត្រឹមត្រូវផងចុះ ។

សូមទ្រង់សណ្តោសប្រណីដល់ពួកយើងនិងឪពុកម្តាយរបស់ពួកយើងព្រមទាំងជនមូស្លីមទាំងអស់ផង ។

وصلى الله على نبينا وعلى آله واصحبه أجمعين

## ៨- មតិបកស្រាយរបស់គណៈកម្មការច្បាប់នៃប្រទេសអេហ្ស៊ីប

គណៈកម្មការសំរាប់ផ្តល់ចំលើយរបស់ប្រទេសអេហ្ស៊ីបបានចេញផ្សាយអំពីច្បាប់សាសនាអ៊ីស្លាមដោយបានដាក់បំរាមដាច់ខាតចំពោះការជក់បារី គឺ



នៅក្នុងឯកសារផ្តល់ចំលើយចេញផ្សាយនៅ ថ្ងៃទី២៩ខែជើម៉ាឌុលអៅវ៉ាល់ឆ្នាំ១៤២០ម.ស ត្រូវនឹងថ្ងៃទី០៩ខែកញ្ញាឆ្នាំ១៩៩៩គ.ស ។

ក្នុងឯកសារនោះបានបញ្ជាក់ថាៈតាមការសិក្សាស្រាវជ្រាវនៅពេលបច្ចុប្បន្ននេះបានបង្ហាញអោយឃើញថាៈ "ការប្រើប្រាស់គ្រឿងញៀនជាការបំផ្លាញមកលើខ្លួនប្រាណ " ដែលក្នុងនោះ គឺការជក់បារី វាធ្វើអោយគ្រោះថ្នាក់ដល់អ្នកជក់ និងអ្នកដែលនៅក្បែរខ្លួនគេផងដែរហើយវាក៏ជាប្រភពនៃការខ្ជះខ្ជាយទ្រព្យសម្បត្តិដែលអល់ឡោះបានហាមឃាត់ ។

- អល់ឡោះមានបន្ទូលនៅក្នុងជំពូកអាន់នីសាកវាក្យខ័ណ្ឌ២៩ថាៈ

**(ولاَ تقْتلُوا أنفُسكُم إِن اللهَ كَانَ بِكُم رحيما)**

មានន័យថាៈ ពួកអ្នកកុំសំលាប់ខ្លួនឯងអោយសោះ ព្រោះអល់ឡោះមានក្តីមេត្តាបំផុតដល់ពួកអ្នក ។

- អល់ឡោះមានបន្ទូលនៅក្នុងជំពូកអាល់ហ្បាការ៉ោះវាក្យខ័ណ្ឌ១៩៥

**( ولاَ تلقُوا بِأَيديكُم إِلىَ التهلُكة وأحسِنوا إِن اللهَ يحب المحسِنِين )**

មានន័យថា ៈ ពួកអ្នកកុំបណ្តោយខ្លួនរបស់ពួកអ្នកអោយធ្លាក់ក្នុងភាពអន្តរាយអោយសោះ ចូរពួកអ្នកព្យាយាមធ្វើអំពើកុសល ព្រោះអល់ឡោះស្រលាញ់អ្នកធ្វើកុសលទាន ។

តាមរយៈភស្តុតាងទាំងនេះបង្ហាញអោយឃើញថាៈ ការជក់បារីត្រូវបានច្បាប់ហាមឃាត់ដោយសំអាងលើការប្រៀបធៀបថ្លឹងថ្លែង( អំពីភាពប្រហាក់ប្រហែលនៃច្បាប់) ពីច្បាប់សាសនាអ៊ីស្លាម ។

*ដកស្រង់ដោយលោកបណ្ឌិតណាសរីហ្វារីតវាស៊ិល ជាអ្នកផ្តល់មតិផ្នែកសាសនាអ៊ីស្លាមនៅឯប្រទេសអេហ្ស៊ីប។*

**៩- មតិបកស្រាយរបស់លោកសាស្ត្រាចារ្យតួនលោកអូសៃមីន**

សំនួរៈ តើច្បាប់នៃការជក់ឬលក់បារីដូចម្តេចដែរ ?

ចំលើយ ៖ ការជក់បារីត្រូវបានច្បាប់សាសនាអ៊ីស្លាមហាមឃាត់ ដូចគ្នាដែរការលក់ ការទិញ និងការជួលកន្លែងសំរាប់អោយគេលក់បារី ពីព្រោះអំពើនោះវាជាការជួយគាំទ្រលើការប្រព្រឹត្តអំពើបាបកម្ម និងភាពជាសត្រូវរបស់សាសនា និងសង្គម។ ភស្តុតាងលើបញ្ហានេះគឺតាមរយៈបន្ទូលរបស់អល់ឡោះដែលមានបន្ទូលនៅក្នុងជំពូកអាន់នីសាកវាក្យខ័ណ្ឌ៥ថាៈ

**(ولاَ تؤتوا السفَهاءَ أموالكُم التي جعلَ اللهُ لكُم قياما) سورة النساء ៖ ៥**

មានន័យថា ៖ **ចូរពួកអ្នក (ឱ បណ្តាអាណាព្យាបាល) កុំផ្តល់អោយជនមិនគ្រប់លក្ខណៈ នូវទ្រព្យសម្បត្តិរបស់ពួកអ្នកដែលអល់ឡោះបានផ្តល់អោយពួកអ្នកសំរាប់ទ្រទ្រង់ជីវិតនោះ។**

វាក្យខណ្ឌនេះបានបង្ហាញថាៈ អល់ឡោះពិតជាបានហាមឃាត់មិនអោយពួកយើងផ្តល់ទ្រព្យសម្បត្តិអោយអ្នកមិនគ្រប់លក្ខណៈឡើយ ព្រោះបុគ្គលដែលមិនគ្រប់លក្ខណៈ គឺគេចំណាយលុយកាក់ទៅលើប្រការដែលមិនផ្តល់ផលប្រយោជន៍។ ទ្រង់បានបញ្ជាក់ថាៈ ទ្រព្យសម្បត្តិទាំងនេះ គឺដើម្បីទ្រទ្រង់ដល់មនុស្សសំរាប់ប្រយោជន៏សាសនា និងជីវភាពរស់នៅលើលោកិយ៏របស់ពួកគេ។ ដូចនេះ បើការចំណាយទៅលើបារី គឺវាមិនមែនផ្តល់ប្រយោជន៏សំរាប់



សាសនា ឬ ផ្តល់ប្រយោជន៏សំរាប់ការរស់នៅលើលោកិយ៏នេះឡើយ។ ការចំណាយលុយកាក់ទៅលើបារី វាផ្ទុយនឹងទិសដៅរបស់អល់ឡោះដែលទ្រង់បានផ្តល់លុយកាក់ សំរាប់មនុស្សលោករបស់ទ្រង់យកទៅប្រើប្រាស់លើផ្លូវល្អ។ ក្នុងចំណោមភស្តុតាងបញ្ជាក់ពីបំរាមជក់បារីនោះ គឺក្នុងបន្ទូលរបស់ទ្រង់នៅ ក្នុងជំពូកអាន់នីសាក វាក្យខ័ណ្ឌ២៩ថាៈ

**(ولاَ تقْتلُوا أنفُسكُم إن اللهَ كانَ بِكُم رحيما)**

មានន័យថាៈ **ពួកអ្នកកុំសំលាប់ខ្លួនឯងអោយសោះ ព្រោះអល់ឡោះមានក្តីមេត្តាបំផុតដល់ពួកអ្នក។**

ចំពោះភស្តុតាងអំពីវាក្យខ័ណ្ឌខាងលើបានបង្ហាញថាៈ ខាងផ្នែកសុខាភិបាលបានបង្ហាញថាៈ ការជក់បារីជាមូលហេតុដែលបង្កអោយមានជម្ងឺរីកលចរិតអាចធ្វើអោយស្លាប់បាន ដូចជាជម្ងឺមហារីកដែរ វាជាហេតុផលនាំដល់ការវិនាសអន្តរាយដល់អ្នកប្រើប្រាស់មិនខាន។

អល់ឡោះមានបន្ទូលនៅក្នុងជំពូកអាល់អាក់រ៉ហ្វវាក្យខ័ណ្ឌ៣១ថាៈ

**(وكُلُوا واشربوا ولاَ تسرفُوا إنه لاَ يحبُ المسرفين) الأعراف៖ ៣១**

**មានន័យថាៈ ចូរពួកអ្នកហូបនិងផឹកចុះ តែពួកអ្នកកុំខ្ជះខ្ជាយអោយសោះ ព្រោះអល់ឡោះមិនស្រលាញ់ចំពោះជនដែលខ្ជះខ្ជាយឡើយ។**

ចំពោះភស្តុតាងអំពីវាក្យខ័ណ្ឌខាងលើបានបង្ហាញថាៈ គ្រាន់តែចំពោះរបស់ដែលច្បាប់អនុញ្ញាតអោយហូបចុក ត្រូវអល់ឡោះហាមឃាត់ពីការខ្ជះខ្ជាយ ចុះទំរាំការចំណាយលុយកាក់ទៅលើរបស់ដែលគ្មានប្រយោជន៏ គឺវា

កាន់តែត្រូវអស់ឡោះហាមឃាត់កាន់តែខ្លាំងទៅទៀត ។

- សាហាវីលោកបានហាមឃាត់ពីការខ្ជះខ្ជាយទ្រព្យសម្បត្តិ ហើយវាគ្មានការមន្ទិលសង្ស័យឡើយចំពោះការចំណាយទ្រព្យសម្បត្តិក្នុងការទិញបារី វាពិតជាការខ្ជះខ្ជាយទ្រព្យសម្បត្តិយ៉ាងពិតប្រាកដមែន នេះវាជាភស្តុតាងមួយផ្សេងទៀត តែបើសំរាប់អ្នកមានសតិបញ្ញាញាណនោះ គឺវាគ្រប់គ្រាន់ហើយ បើមានភស្តុតាងពីគម្ពីរអាល់គួរអាន ឬពីមាគិារបស់សាហាវីរបស់ទ្រង់ ។

- រីឯការពិនិត្យជាក់ស្តែងចំពោះការដាក់បំរាមវិញបង្ហាញថាៈ សំរាប់អ្នកមានសតិបញ្ញាញាណនោះ គេនឹងមិនបរិភោគអ្វីមួយដែលជាហេតុនាំរូបគេមានគ្រោះថ្នាក់ឬមានជំងឺដង្កាត់នោះឡើយ គេត្រូវតែគិតដល់ផលចំណេញពីការចំណាយរបស់គេ ព្រោះអ្នកមានសតិបញ្ញាញាណ គេត្រូវការពារខ្លួនប្រាណនិងទ្រព្យសម្បត្តិរបស់គេជានិច្ច គេនឹងមិនធ្វេសប្រហែសក្នុងករណីនេះឡើយវាលែងតែជនខ្វះការពិចារណាប៉ុណ្ណោះ ។ ក្នុងចំណោមភស្តុតាងជាក់ស្តែងបង្ហាញពីបំរាមចំពោះការជក់បារី គឺអ្នកជក់បារី ពេលណាគេគ្មានបារីទេធ្វើអោយក្នុងទ្រូងរបស់គេខ្វល់ខ្វាយ ចង្អៀតចង្អល់ និងធ្វើអោយអារម្មណ៏របស់គេចង់តែជក់ ។ អារម្មណ៏របស់គេនឹងមិនស្រស់ថ្លាទេលុះត្រាតែគេបានជក់វិញ មិនតែប៉ុណ្ណោះវាធ្វើអោយអ្នកជក់នោះពិបាកខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចចំពោះអល់ឡោះដូចជាការអំណត់បួសជាដើម ។ អ្នកជក់បារីបួសរបស់គេមានភាពតឹងតែង និងធ្ងន់ធ្ងរ ណាស់សំរាប់រូបគេ ពីព្រោះការបួសត្រូវបានច្បាប់ហាមឃាត់មិនអោយជក់ និងមិនអោយទទួលទាន



អាហារចាប់ពីមានពន្លឺពណិសនៅជើងមេឃទិសខាងកើតរហូតដល់ ថ្ងៃលិចឯនោះ ។ វាអាចថាការកាន់អំណត់បួសចំរដូវក្តៅមានរយៈពេលវែងទៀតនោះវាធ្វើអោយការបួសរបស់គាត់ ក្លាយជាទង្វើដែលគាត់ស្អប់ខ្ពើមដែលពិបាកទទួលយក ។

*ដូចនេះខ្ញុំដាស់តឿនរំលឹកដល់បងប្អូនអ៊ីស្លាមទាំងអស់ថាៈ*

សូមកុំជក់ កុំលក់ កុំទិញ កុំជួលកន្លែងអោយគេ សំរាប់ការលក់បារីនិងកុំជួយគាំទ្រការប្រើប្រាស់បារីអោយសោះទោះបីក្នុងហេតុផលណាមួយក៏ដោយចុះ ។

## ១០ - មតិបកស្រាយរបស់លោកសាស្ត្រាចារ្យមូហាំម៉ាត់ត្វូនលោកអ៊ីប្រាហ៊ីម

មានគេសួរខ្ញុំអំពីច្បាប់នៃការប្រើប្រាស់ថ្នាំជក់ដែលភាគច្រើននៃជនអវិជ្ជា និងខ្វះសតិបញ្ញាបាននឹងកំពុងពេញនិយមប្រើវា ដោយម្នាក់ៗគេបានដឹងថាពួកយើងដាក់បំរាមលើការប្រើប្រាស់វា ដូចគ្នាដែរសាស្ត្រាចារ្យរបស់យើងពីមុនៗមក និងថ្នាក់ដឹកនាំជាច្រើននៅឯណាច់ឌី និងបណ្តាសាសនវិទូជាច្រើនទៀតតាំងតែពី១០០០ឆ្នាំនៃគ.សមកហើយ រហូតដល់ពេលបច្ចុប្បន្ន ដោយផ្អែកលើមូលដ្ឋានគ្រឹះនៃច្បាប់សាសនាអ៊ីស្លាមនិងផ្អែកសុខាភិបាល ។ ខ្ញុំសូមបញ្ជាក់ថាៈបារីគឺមិនល្អឡើយវាធ្វើអោយញៀន និងពុល ។ ការបង្ហាញថាៈ ការជក់បារីត្រូវច្បាប់ហាមឃាត់គឺតាមរយៈភស្តុតាងត្រឹមត្រូវតាមការវិភាគដ៏ច្បាស់លាស់និងតាមការពិនិត្យរបស់វេជ្ជបណ្ឌិតជាច្រើនផងដែរ ។

## ភស្តុតាងដែលបង្ហាញពីការហាមឃាត់គឺ៖

- បន្ទូលរបស់អល់ឡោះនៅក្នុងជំពូកអាល់អាក់រ៉ហ្វវាក្យខ័ណ្ឌ១៥៧ថា៖

**( الذين يتبعونَ الرسولَ النبي الأمي الذي يجدونه مكتوبا عندهم في التوراة والإنجيل يأمرهم بالمعروف وينهاهم عن المنكر ويحل لهم الطيبات ويحرم عليهم الخبائثَ) الأعراف:**១៥៧

មានន័យថា៖ បណ្តាអ្នកដែលប្រតិបត្តិតាមរ៉សូលដោយលោកជាសាហាវីមិនចេះអានមិនចេះសរសេរដែលពួកគេបានដឹងពីលក្ខណៈរបស់លោកដែលត្រូវបានបញ្ជាក់ប្រាប់នៅក្នុងគម្ពីរតាវ៉រតនិងគម្ពីរអ៊ិនជីល។ ទ្រង់បញ្ជាពួកគេអោយសាងតែកុសលល្អ និងហាមឃាត់ពួកគេពីការសាងអំពើអាក្រក់ ហើយទ្រង់បានអនុញ្ញាតដល់ពួកគេអោយបរិភោគនូវចំណី អាហារល្អៗ និងទ្រង់បានដាក់បំរាមលើពួកគេនូវចំណីអាហារទាំងឡាយណា ដែលអាក្រក់។

នៅក្នុងសៀវភៅសហេសពូខរីបានបញ្ជាក់ថា៖អ៊ិបនូអ៊ូម៉ើរនិយាយថាសាហាវីមូហាំម៉ាត់បានមានប្រសាសន៍ថា៖

**( كُل مسكر خمر وكُل خمر حرام)**

មានន័យថា៖ រាល់អ្វីៗដែលស្រវឹងគឺចាត់ទុកថាជាសុរា ហើយរាល់សុរាទាំងអស់គឺត្រូវបានច្បាប់ហាមឃាត់។ នៅក្នុងសេចក្តីរាយការណ៏របស់អ៊ីម៉ាំមូស្លីមថា៖**(كُل مسكر حرام)**មានន័យថា៖រាល់គ្រឿងស្រវឹកគឺហារ៉ាំ (បំរាមដាច់ខាត)។

នៅក្នុងសៀវភៅសហេសពូខរីនិងមូស្លីម បានបង្ហាញថា៖ណាហ្គីបានមាន



ប្រសាសន៏ថា "ជាការពិតណាស់អល់ឡោះបានដាក់បំរាមលើពួកអ្នកប្រព្រឹត្តអកតញ្ញូចំពោះម្តាយ សំលាប់កូនស្រីដោយកប់ទាំងរស់ ក្មេងក្មាងនិងខ្វះសុជីវធម៌ហើយទ្រង់ស្អប់ខ្ពើមចំពោះពាក្យសំដីចចាមអារាម ការសួរដេញដោលច្រើន និងការបំផ្លាញទ្រព្យសម្បត្តិ ឬខ្ជះខ្ជាយទ្រព្យសម្បត្តិ។

យើងនឹងលើកយកមកបង្ហាញនូវទស្សនៈរបស់សាសនវិទូអ៊ីស្លាមនៅក្នុងមាគ៌ារបស់អ៊ីម៉ាំទាំងបួន ដូចតទៅ ៖

-សាសនាវិទូអ៊ីស្លាមក្នុងនិកាយអ៊ីម៉ាំហាណាហ្វីគឺលោកមូហាំម៉ាត់អាល់អៃនីបានបញ្ជាក់នៅក្នុងសៀវភៅរបស់លោកថា ហាមដាច់ខាតក្នុងការជក់បារីដោយសារមូលហេតុ៤ យ៉ាងដូចខាងក្រោម ៖

**ទី១**-បារីបង្កផលប៉ះពាល់ដល់សុខភាពតាមរយៈការបង្ហាញជាផ្លូវការរបស់វេជ្ជបណ្ឌិតជំនាញៗជាច្រើនរូប ហើយនៅក្នុងច្បាប់សាសនាអ៊ីស្លាមគឺហាមរាល់សារធាតុទាំងឡាយណាដែលបង្កផលប៉ះពាល់ដល់សុខភាព ដោយការឯកភាពទាំងស្រុង។

**ទី២**-បារីវាស្ថិតក្នុងប្រភេទគ្រឿងញៀនតាមការឯកភាពពីសាសនវិទូអ៊ីស្លាមវាត្រូវបានច្បាប់សាសនាអ៊ីស្លាមហាមឃាត់ក្នុងការប្រើប្រាស់វា ដោយយោងតាមសេចក្តីរាយការណ៏ហាហ្វីស្ស ដោយអ៊ីមាំអះម៉ាត់អំពីម្តាយសាឡាម៉ះបានបញ្ជាក់ថារ៉សូលុលឡោះបានហាមឃាត់នូវរាល់វត្ថុ ដែលនាំអោយស្រវឹងឬពុល និងបាត់បង់ស្មារតីនេះគឺស្របគ្នានឹងការអះអាងពីបណ្តាវេជ្ជបណ្ឌិតទាំងអស់។ អំណះអំណាងរបស់វេជ្ជបណ្ឌិតក៏ជាភស្តុតាងដែរ នេះជាទស្សនៈ

ឯកភាពគ្នារវាងសាសនវិទូផ្នែកច្បាប់សាសនាសម័យមុននិងសម័យបច្ចុប្បន្ន ។

**ទី៣-** បារីជាវត្ថុដែលមានក្លិនស្អុយអាក្រក់ធ្វើអោយប៉ះពាល់និងរំខានដល់អ្នកដទៃដែលមិនប្រើប្រាស់វា ជាពិសេសនៅពេលសឡាហ៍រួមជាដើម និងវាបានធ្វើអោយរំខានដល់ពួកម៉ាឡាអ៊ីកាហ៍ផងដែរ ។ ភស្តុតាងបានបង្ហាញថា: អំពីលោកជើហ្បៀរបានបញ្ជាក់ថា: ណាប៊ីបានមាន ប្រសាសន៍ថា:

**(من أَكَلَ ثَوما أو بصلاً فَلْيعتزلْنا وليعتزلْ مسجِدنا وليقْعد في بيته)رواه البخاري ومسلم**

មានន័យថា: បុគ្គលណាពិសារខ្ទឹមស ឬខ្ទឹមបារាំង ចូរអោយគេចេញឆ្ងាយពីពួកយើងនិងអោយគេចាកចេញពីម៉ាស្ជិតរបស់យើង សូមអោយគេនៅក្នុងផ្ទះរបស់គេទៅ( *រាយការហាហ្ទីស្សដោយអ៊ីម៉ាំពូខរីនិងមូស្លីម*) ។

យើងដឹងហើយថា: ក្លិនស្អុយរបស់បារីមិនអន់ជាងក្លិនស្អុយរបស់ខ្ទឹមសនិងខ្ទឹមបារាំងនោះឡើយ ។

- នៅក្នុងសៀវភៅសហេសពូខរីនិងមូស្លីមបានបញ្ជាក់ថា: អំពីលោកជើហ្បៀរបានបញ្ជាក់ថា: ណាប៊ីបានមានប្រសាសន៍ថា:

**(أن الملائكةَ تتأذى مما يتأذى منه الناس) رواه البخاري ومسلم**

មានន័យថា: ពួកម៉ាឡាអ៊ីកាហ៍ពិតជាត្រូវទទួលការរំខានតាមរយៈការរំខានទាំងឡាយណាដែលគេធ្វើទៅលើមនុស្សលោកនោះ ។

- នៅក្នុងហាហ្ទីស្សរបស់លោកអាណាសបញ្ជាក់ថា: ណាប៊ីបានមានប្រសាសន៍ថា:



**(من أذَى مسلما فَقَد آذَاني ومن آذَاني فَقَد آذَى الله)** رواه الطبراني بإسناد حسن

មានន័យថា: បុគ្គលណាបានធ្វើទុក្ខបុកម្នេញលើជនមូស្លីមណាម្នាក់ ប្រៀបបាននឹងគេធ្វើទុក្ខបុកម្នេញលើរូបខ្ញុំដែរ( ណាប៊ី ) ហើយបុគ្គលណាបានធ្វើបុកទុក្ខម្នេញមកលើរូបខ្ញុំ គេប្រៀបបានធ្វើទុក្ខបុកម្នេញលើអល់ឡោះដែរ ។ ( *រាយការណ៍ដោយអ៊ីម៉ាំតប់រ៉ានី*) ។

**ទី៤** - បារីនាំឱ្យមានការខ្ជះខ្ជាយ វាមិនមែនជារបស់មួយដែលនាំមកនូវផលប្រយោជន៍ក្រៅពីផលប៉ះពាល់នោះឡើយ ផ្ទុយទៅវិញផលប៉ះពាល់របស់វាគឺមានពិតប្រាកដតាមការអះអាងដ៏ជាក់លាក់របស់អ្នកជំនាញ ។

ក្នុងចំណោមអ្នកជំនាញទាំងនោះគឺ លោកអាហ្មូអាល់ហាសាន់ជនជាតិអេហ្ស៊ីប ក្នុងនិកាយហាណាហ្វីបានលើកឡើងថា: ផ្អែកតាមភស្តុតាងដ៏ត្រឹមត្រូវនិងការវិភាគដ៏ច្បាស់លាស់បានបង្ហាញ និងប្រកាសឱ្យដឹងពីការហាមឃាត់ក្នុងការជក់បារី ។ វាបានកើតមាននៅក្នុងអំឡុងឆ្នាំ១០០០នៃគ.សកើតចេញដំបូងគេបង្អស់ គឺនៅឯទឹកដីពួកយ៉ើហ៊ូឌី ណាសរ៉នី និងម៉ាយូស៊ី ហើយក៏មានបុរសយ៉ើហ៊ូឌីម្នាក់បាននាំវត្ថុនេះមក ។ គេបានគិតថាពិតណាស់គេជាបុរសត្រឹមត្រូវឈ្លាសវៃម្នាក់ ដែលបាននាំវាទៅកាន់ទឹកដីម៉ូរ៉ូកូហើយគេបានបញ្ចុះបញ្ចូលមនុស្សលោកប្រើប្រាស់វា ។ អ្នកដែលអូសទាញគេទៅកាន់ទឹកដីរ៉ូមដំបូងគេបង្អស់គឺបុរសម្នាក់ឈ្មោះថា: "**អាល់អាតាកាលីន** " មកពីសាសនាណាសរ៉នី ។ អ្នកបញ្ចេញថ្នាំជក់ដំបូងគេបង្អស់ទៅប្រទេសស៊ូដង់គឺអ្នកកាន់សាសនាម៉ាយូស៊ីម្នាក់ ក្រោយមកគាត់បាននាំបារីទៅកាន់ប្រទេសអេហ្ស៊ីប

និងហ៊ីជើស្ស ( តំបន់អារ៉ាប់ ) និងគ្រប់ទិសទីទាំងអស់ ។

អល់ឡោះពិតជាបានដាក់បំរាមចំពោះសារធាតុដែលធ្វើអោយស្រវឹងពុលបាត់បង់ស្មារតី ។បើគេឆ្លើយថា: "វាមិននាំអោយស្រវឹងឬពុលនោះទេ!បើមិនស្រវឹងឬពុលក៏វាជាប្រភេទគ្រឿងញៀន និងបង្កផលប៉ះពាល់ដល់អវយវៈរបស់អ្នកប្រើប្រាស់ទាំងផ្នែកខាងក្រៅនិងខាងក្នុងជាមិនខាន ។ ពាក្យថា "ស្រវឹង ឬពុល" នោះមានន័យថា: វាធ្វើអោយបាត់បង់វិចារណញាណទោះបីវាមិនធ្ងន់ធ្ងរក៏ដោយជាពិសេសចំពោះអ្នកជក់បារីថ្មីថ្មោងបើវាមិនដល់កំរិតស្រវឹងឬពុល ក៏វាធ្វើអោយវិលមុខធឹងធោងក្នុងខ្លួនដែរ ។

-សេចក្តីរាយការណ៍របស់អ៊ីមាំអះម៉ាត់ និងអាហ៊្ពីដាវូដអំពីអ៊ុំមូសាឡាម៉ះបានអះអាងថា: "រ៉ស៊ូលុលឡោះបានដាក់បំរាមរាល់វត្ថុដែលធ្វើអោយស្រវឹងឬពុលនិងអោយសរីរាង្គទន់ខ្សោយ ។

បណ្តាសាសនវិទូអ៊ីស្លាមបានបង្ហាញថា: សារធាតុណាដែលធ្វើអោយបាត់បង់សុខភាពដែលវាបានបន្សល់នូវភាពអន្តរាយ និងការញៀនគ្រប់រូបភាពទាំងអស់គឺត្រូវបានច្បាប់ហាមឃាត់ ដោយអនុលោមតាមហាហ្ទីស្សដែលបញ្ជាក់ពីការហាមឃាត់ ពីព្រោះធ្វើអោយប៉ះពាល់ និងគ្រោះថ្នាក់ដល់រាងកាយ និងវិញ្ញាណសតិស្មារតីព្រមទាំងបំផ្លាញបេះដូង ធ្វើអោយកំលាំងពលំចុះទន់ខ្សោយទៅៗ និងធ្វើអោយស្បែកឡើងពណ៌លឿង ។

- តាមការអះអាងរបស់វេជ្ជបណ្ឌិតទាំងអស់បានបញ្ជាក់ថា: បារីគឺនាំអោយគ្រោះថ្នាក់ គឺវាធ្វើអោយគ្រោះថ្នាក់ដល់ខ្លួនប្រាណ រាងកាយ កិត្តិយស និង



ទ្រព្យសម្បត្តិ ពីព្រោះថាជាធម្មតាអ្នកប្រើប្រាស់គឺច្រើនតែអ្នកបំពានច្បាប់ហើយវាធុំក្លិនស្អុយមាត់ទៀតផង ។

-នៅក្នុងចំណោមសាសនវិទូផ្នែកច្បាប់នៃក្រុមអ៊ីមាំហាំហ្ពើលីគឺលោកអាប់ឌុលឡោះកូនលោកមូហាំម៉ាត់កូនលោកអាប់ឌុលវ៉ាស់ហ៊ើបបានបញ្ជាក់ថា: នៅពេលឆ្លើយតបអំពីការចោទសួរលើការប្រើប្រាស់ថ្នាំជក់ បន្ទាប់ពីបានបង្ហាញនូវភស្តុតាងចំពោះការហាមឃាត់គ្រឿងស្រវឹង លោកបានលើកមកបង្ហាញនៃមតិរបស់អ្នកមានវិជ្ជាថា: " អ្វីដែលយើងបានយកមកបង្ហាញតាមរយៈប្រសាសន៏របស់រ៉ស៊ូលុលឡោះ និងទស្សនៈនៃអ្នកមានវិជ្ជាជាច្រើនបង្ហាញយ៉ាងច្បាស់ថា: ថ្នាំជក់និងគ្រឿងញៀនត្រូវបានគេហាមឃាត់ចំពោះពួកអ្នកដែលមនុស្សភាគច្រើន សម័យបច្ចុប្បន្នយើងកំពុងបានប្រើប្រាស់វាយ៉ាងកុះករនោះ ។ យើងបានដឹងនិងឃើញយ៉ាងច្បាស់គេមានសភាពល្ងីល្ងើ នៅពេលខ្លះជាក់ស្តែងពេលណាគេប្រើប្រាស់ច្រើន ឬពេលណាគេមិនប្រើប្រាស់មួយថ្ងៃឬពីរថ្ងៃ តែក្រោយមកបើគេចាប់ផ្តើមប្រើប្រាស់វាឡើងវិញ គឺវានឹងធ្វើអោយបុគ្គលនោះស្រវឹងនិងបាត់បង់ស្មារតីវិចារណញ្ញាណ រហូតដល់បុគ្គលនោះនិយាយជាមួយអ្នកដទៃ ទាំងមិនដឹងថាគេនិយាយពីអ្វីផង ។ យើងសុំពីអល់ឡោះសូមទ្រង់ការពារពួកយើងពីអំពើអ្វីដែលសង្គមស្អប់ខ្ពើម និងអាកប្បកិរិយាមិនគប្បីទាំងនេះផងចុះ ។ មិនគប្បីទេចំពោះអ្នកមានជំនឿនឹងអល់ឡោះ និងជំនឿនឹងថ្ងៃបរលោកបែរជាងាកទៅទទួលយកទស្សនៈបុគ្គលណាម្នាក់ក្នុងចំនោមមនុស្សលោកពេលណាហើយបន្ទូលរបស់អល់ឡោះ

និងប្រសាសន៍រ៉ស៊ូលរបស់ទ្រង់បានបញ្ជាក់ពីក្រឹត្យក្រមច្បាប់ហើយនោះព្រោះថាៈ ការប្តេជ្ញាទទួលស្គាល់រ៉ស៊ូលរបស់អល់ឡោះ មានន័យថាគឺចាំបាច់ត្រូវប្រតិបត្តិនូវអ្វីដែលលោកបានបង្គាប់បញ្ជា ហើយត្រូវជៀសអោយឆ្ងាយពីអ្វីដែលលោកបានហាមឃាត់ ព្រមទាំងត្រូវជឿជាក់នូវអ្វីដែលលោកបានផ្តល់មក។

នៅក្នុងចំនោមសាសនវិទូផ្នែកច្បាប់សាសនាអ៊ីស្លាមនៃក្រុមអ៊ីមុាំស្ហ៊ីហ្វីអ៊ីគឺលោកអាល់អ៊ីស៊្រិបាននិយាយថាៈ ថ្នាំជក់និងគ្រឿងញៀនគឺចាប់ផ្តើមមាននៅទីក្រុងឌីមីស(ទីក្រុងរបស់ប្រទេសស៊ីរី)ក្នុងឆ្នាំទី១០១៥នៃគ.ស ដោយអ្នកប្រើប្រាស់គេបានអះអាងថា វាមិននាំអោយស្រវឹង ឬពុលនោះទេ។ តាមពិតបើវាមិនដល់កំរិតស្រវឹងឬពុលក៏ដោយក៏វាធ្វើអោយបាត់បង់កំលាំងកាយ និងស្មារតីដែរ។ ត្រឹមកំរិតនេះក៏ដោយ ក៏ត្រូវច្បាប់ហាមដែរដោយអនុលោមតាមរយៈហាហ្ទីស្សនាំមកដោយអ្នកស្រីអ៊ុម្មូសាឡាម៉ះ បានបង្ហាញថាៈ ពិតណាស់រ៉ស៊ូលុលឡោះបានដាក់បំរាមរាល់សារធាតុដែលធ្វើអោយស្រវឹងឬពុលនិងបាត់បង់វិចារណញ្ញាណ (*រាយការណ៍ដោយអ៊ីមុាំអះម៉ាត់*) នៅមានសាសនវិទូជាច្រើនទៀតដែលមានទស្សនៈពីការហាមឃាត់ការជក់បារីដូចជាៈ

- សាសនវិទូមកពីម៉ូរ៉ូកូ គឺលោកអាហ្មួអាល់ហ្គយស៊ីអាល់ហ្វាសើស៊ីក្នុងមាគ៌ាអ៊ីមាំម៉ាលីគី។
- សាសនវិទូមកពីប្រទេសយ៉េមែន គឺលោកអ៊ីបរ៉ហ៊ីមកូនជាំអាន និងសិស្សរបស់លោកគឺអាហ្មួហ្គាកើរអាល់អះឌីល។
- សាសនវិទូមកពីប្រទេសអារ៉ាប៊ីសាអ៊ូឌីត គឺអាប់ឌុលម៉ាលិកអាល់អាសរម៉ីនិងសិស្សរបស់លោកគឺមូហាំម៉ាត់កូនអ៊ីឡើ ដែលជាអ្នកអត្ថាធិប្បាយនៅក្នុងសៀវភៅរីយ៉ឺឌិសសាលីហ៊ីននិងលោកអូម៉ើរអាល់ហ្គាសរី។
- សាសនវិទូមកពីស្រុកអាល់រ៉ូមីយ៉ះ គឺលោកមូហាំម៉ាត់អាល់ខវ៉ាយ៉ះ និងលោកអ៊ីសើអាសសើហ៊ើឌីក្នុងមាគ៌ាហាណាហ្វី និងលោកម៉ាក់គីកូនលោកហ្វើរូខនិងលោកសាអាត់អាល់ហ្គើឡាឃីសអាល់ម៉ាដានីនិងលោកមូហាំម៉ាត់អាល់ហ្គើរហ្សានឃីអាល់ម៉ាដានីក្នុងមាគ៌ាអ៊ីមុាំសាហ្វីអ៊ី។សាសនវិទូទាំងនេះគឺជាសាសនវិទូរបស់ពលរដ្ឋអ៊ីស្លាមជំនាន់នេះជាថ្នាក់ដឹកនាំកំពូលរបស់យើងពួកគេបានបង្ហាញប្រាប់ពីការហាមឃាត់ការជក់បារី និងការប្រើប្រាស់គ្រឿងញៀន និងការជួយទៅលើទង្វើទាំងអស់នេះ។ គេតែងតែសង្កេតឃើញថាៈ ចំពោះអ្នកប្រើប្រាស់បារីពេលណាមានជំលោះអ្វីមួយគេរំលឹកដល់បុគ្គលនោះថាៈ ចូរអ្នកសូត្រកើលីម៉ាស់ហ្សៃហ៊ើឌះ? បុគ្គលនោះតែងតែតបមកគេវិញថាៈ បារីវាក្តៅណាស់!!!

## គតិត្រឹមត្រូវៈ

តាមការយល់ដឹងច្បាស់លាស់ ការសាកល្បង និងការមើលឃើញធាតុពិតជាក់ស្តែងទៅលើអ្នកប្រើប្រាស់បារីភាគច្រើនទទួលរងនូវ ផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព ខ្លួនប្រាណ និងប្រាជ្ញាស្មារតីរបស់អ្នកជក់។ វាពិតជានាំមកនូវសេចក្តីស្លាប់ ការសន្លប់បាត់ស្មារតី និងជំងឺដ៏ធ្ងន់ធ្ងរផ្សេងៗ ដូចជាក្អកជា

ដើម ដែលបណ្តាលទៅជាជំងឺរបេង ជំងឺបេះដូង ហើយស្លាប់ដោយសារគាំងបេះដូងជាដើម ។

## ការជាស់តឿនរំលឹករបស់វេជ្ជបណ្ឌិតៈ

សាសនវិទូជំនាន់មុនៗបានឯកភាពគ្នាអោយមានការប្រុងប្រយ័ត្ន ចំពោះបីចំនុចដោយពួកគេបានយល់ស្របគ្នាពីផលប៉ះពាល់របស់វាៈ

**ទីមួយ :** វត្ថុទាំងឡាយណាដែលមានក្លិនស្អុយអាក្រក់ ។

**ទីពីរ :** ធូលី ។

**ទីបី :** បារី ថ្នាំញៀននិងគ្រឿងស្រវឹង ។

ចំណែកអ្នកជំនាន់ក្រោយមួយចំនួនដែលទទួលនូវរុក្ខជាតិដ៏អាក្រក់ទាំងនេះផងដែរ ។ យើងសូមសង្ខេបនូវអ្វីដែលពួកគេបានរំលឹកពីផលប៉ះពាល់របស់វា ។

## ខាងក្រោមនេះ ជាការសង្ខេបនូវអ្វីដែលគេបានរំលឹក :

គេបាននិយាយថាៈ វាគឺជារុក្ខជាតិដែលមានជាតិពិស រសជាតិល្វីង ។ ក្រោយពីធ្វើការបញ្ជាក់ និងសាកល្បងបានបង្ហាញថាគឺជាប្រភេទថ្នាំជក់ដែលនៅក្នុងក្រុមនៃរុក្ខជាតិ ដែលចាត់ទុកថាជាប្រភេទរុក្ខជាតិដែលមានជាតិពុលដ៏ខ្លាំងដូចជាថ្នាំស្លឹកជាដើមដែលផ្សំឡើងពីជាតិស្អិតនិងជាតិនីកូទីន ។ គេបាននិយាយថាវាជាប្រភេទរុក្ខជាតិដែលមានជាតិពុលខ្លាំងបំផុត ។ វត្ថុទាំងនេះគេយកមកប្រើប្រាស់ដូចខាងក្រោម :



១-គេប្រើប្រាស់វាដោយទំពានឹងមាត់ ។នេះគឺជាការប្រើប្រាស់ដ៏អាក្រក់ និងគ្រោះថ្នាក់បំផុត ពីព្រោះវាស្ថិតក្នុងប្រភេទវត្ថុញៀនដ៏ខ្លាំង ។ ជាតិពុលរបស់វាចូលទៅក្នុងក្រពះយ៉ាងរហ័ស ហើយវាជ្រាបចូលតាមសរសៃប្រសាទយ៉ាងឆាប់បំផុត ។

២- គេប្រើប្រាស់វាដោយយកវាធ្វើជាម្សៅសំរាប់យកមកហិត ។ វាពិតជាបង្កនូវភាពគ្រោះថ្នាក់ដោយហេតុថាវាផ្សំដោយជាតិពុលយ៉ាងខ្លាំង ។

៣- គេប្រើប្រាស់វាដោយយកវាមកជក់តាមវិធីធ្វើជាបារី ។ វាជាសារធាតុខ្លាំងពីព្រោះការជក់នាំអោយមានកំដៅខ្លាំងនៅក្នុងមាត់ ។ ពិតណាស់បណ្ឌិតវេជ្ជបណ្ឌិតបានកំណត់យ៉ាងជាក់លាក់ថាៈបារីពិតជានាំអោយគ្រោះថ្នាក់បំផុត ។ ដំបូងវាបង្កគ្រោះថ្នាក់នៅក្នុងខ្លួន ក្រោយមកទើបវាបង្ហាញចេញមកក្រៅបន្តិចម្តងៗ ។ ចូរអ្នកចងចាំថាៈផ្សែងដែលហុយចេញពីស្លឹកថ្នាំដែលគេដុត នោះគឺពោរពេញដោយជាតិពុលច្រើនណាស់វាជាជាតិនីកូទីន ។ ជាតិនេះពេលវាចូលទៅក្នុងមាត់ និងសួត គឺវាបង្កគ្រោះថ្នាក់ខ្លាំង ពីព្រោះពេលវាចូលក្នុងមាត់ជាតិពុលឆ្លបង្កអោយមានស្លេស្ម ហើយក៏ធ្វើអោយសាពាង្គកាយ ពោរពេញទៅដោយភាពស្រៀវស្រើបយ៉ាងខ្លាំង និងមានការលំបាកក្នុងការដកដង្ហើមធ្វើអោយក្រពះចុះខ្សោយលំបាកក្នុងការរំលាយ វាក៏បានបង្កដល់អ្នកនូវការវិលមុខ តប់ប្រមល់ ក្អួត ឈឺក្បាល ធ្វើអោយសាច់ដុំចុះខ្សោយជាមូលហេតុនាំដល់ភាពអន្តរាយដោយកើតឡើងបន្តិចម្តងៗ ឬយ៉ាងធ្ងន់ធ្ងរភ្លាមៗតែម្តងវាអាស្រ័យលើការប្រើប្រាស់របស់គេនោះ តិចឬច្រើនប៉ុណ្ណោះ

ដូចជាវាធ្លាប់កើតឡើងលើបងប្អូនបង្កើតពីរនាក់ដែលម្នាក់ស្លាប់ក្នុងអាយុ១៧ ឆ្នាំ និងម្នាក់ទៀតស្លាប់ក្នុងអាយុមិនទាន់គ្រប់១៨ឆ្នាំផង។ ប្រការដែលប៉ះពាល់ដែរនោះគឺនាំអោយខូចគ្រាប់ឈាម និងប៉ះពាល់ទៅដល់បេះដូងដោយរំខានដល់ប្រព័ន្ធនៃចលនារបស់វានិងនាំដល់ការធុំចំណីអាហារ។ គ្រប់សាសនវិទូល្បីៗ និងក្រុមវេជ្ជបណ្ឌិតពិតជាបានរំលឹកថាប្រាកដណាស់អ្នកដែលមានសតិបញ្ញាញាណចាំបាច់ត្រូវជៀសវាងពីការជក់បារី និងគ្រឿងស្រវឹងផ្សេងៗដើម្បីថែរក្សាសុខភាព ដែលនាំអោយគ្រោះថ្នាក់ និងបំផ្លាញដល់ជីវិត ហើយជាពិសេសនោះគឺនាំអោយសាពាង្គកាយចុះខ្សោយឆាប់ចូលវ័យជរា ដែលមិនអាចមានកំលាំងគ្រប់គ្រាន់ប្រឆាំងនឹងជំងឺផ្សេងៗ។ ដូចនេះក៏មានមនុស្សជាច្រើនបានបោះបង់ដោយខ្លាចការគ្រោះថ្នាក់របស់វានិងស្អប់ខ្ពើមក្លិនរបស់វាហើយពិតណាស់វាក៏នាំដល់ការកើតឡើងនូវការលែងលះភរិយារបស់គេ

ប្រសិនបើគេ

វិលត្រឡប់ទៅរកបារីវិញនោះ។គេធ្វើដូចនេះគឺរូបគេចង់បញ្ឈប់ជារៀងរហូតតែបើគេនៅតែមានបំណងចង់បន្តជក់វាទៀតនោះគេពិតជាគ្មានលទ្ធភាពផ្តាច់វាបានទេដូចនេះគេពិតជាងប់នឹងសារធាតុនោះមិនខាន។គេលែងភរិយារបស់គេគឺគេពិតជាសោកស្តាយហើយវាអាចជះឥទ្ធិពលដល់ស្មារតីរបស់គេផងដែរព្រោះអ្នកប្រើប្រាស់វា គេនឹងវិលទៅរកការប្រើប្រាស់វាវិញជាមិនខានពេលដែលគេធ្លាក់ខ្លួនចូលក្នុងភាពងងឹតសូន្យឈឹងនៃស្មារតីហើយនោះ។

**១១- មតិបកស្រាយរបស់លោកសាស្ត្រាចារ្យអាប់ឌុលរ៉ម៉ានអាស្សារ៉ាក់ឌី**



ពីអាលីហាំឌីអាស្សាលីហ៊ី ជូនចំពោះលោកសាស្ត្រាចារ្យអាប់ឌុលរ៉ម៉ានណាសៀរអាស្សារ៉ាក់ឌី សូមលោកសាស្ត្រាចារ្យបំភ្លឺពីច្បាប់ជក់បារី និងការលក់ដូរវាអោយបានច្បាស់ផងថា តើវាត្រូវបានច្បាប់ហាមឃាត់ឬគ្រាន់តែជាប្រការដែលគប្បីចៀសវាង?

ចំលើយ: សូមការចង្អុលបង្ហាញពីអល់ឡោះដល់រូបខ្ញុំបាទនិងបណ្តាមូស្លីម។ ការជក់បារីការលក់និងចែកចាយវា គឺវាត្រូវបានច្បាប់ហាមឃាត់ដាច់ខាត។ វាមិនត្រូវបានច្បាប់អនុញ្ញាតក្នុងការជក់ការប្រើប្រាស់និងការជួញដូរវានោះឡើយ។ ចំពោះបុគ្គលណាដែលប្រើប្រាស់វា ចាំបាច់គេត្រូវសារភាពកំហុសចំពោះអល់ឡោះ នូវការសារភាពចំពោះអល់ឡោះយ៉ាងពិតប្រាកដ វាដូចជាត្រូវសារភាពពីកំហុសផ្សេងៗដែរ។ពិតណាស់ប្រការនេះវាស្ថិតនៅក្រោមភស្តុតាងទូទៅដែលបញ្ជាក់ពីការដែលច្បាប់បានហាមឃាត់ព្រោះផលប៉ះពាល់របស់វាគឺបំផ្លាញទាំងសាសនា ទាំងរាងកាយ និងទ្រព្យសម្បត្តិទៀតផង។

**១- ផលប៉ះពាល់ផ្នែកសាសនា:**

ភស្តុតាងបញ្ជាក់អំពីការហាមឃាត់និងមិនអនុញ្ញាតនោះ មានច្រើនដូចជា:

- អល់ឡោះមានបន្ទូលនៅក្នុងជំពូកអាល់អាក់រ៉ហ្វ វាក្យខ័ណ្ឌទី១៥៧ថា:

**(ويحل لهم الطيبات ويحرم عليهم الخبائثَ) الأعراف:**១៥៧

មានន័យថា: "ហើយទ្រង់បានអនុញ្ញាតដល់ពួកគេអោយបរិភោគនូវចំណីអាហារស្អាតស្អំ និងទ្រង់បានដាក់បំរាមលើពួកគេនូវចំណីអាហារ ទាំងឡាយណាដែលអាក្រក់"។

- អល់ឡោះមានបន្ទូលនៅក្នុងជំពូកអាល់ហ្គាការ៉ោះវាក្យខ័ណ្ឌ១៩៥

( ولا تلقوا بأيديكم إلى التهلكة وأحسنوا إن الله يحب المحسنين ) البقرة:១៩៥

មានន័យថា : ចូរពួកអ្នកកុំបណ្តោយខ្លួន អោយធ្លាក់ក្នុង ភាពអន្តរាយអោយសោះ ចូរពួកអ្នកព្យាយាមធ្វើអំពើកុសល ព្រោះអល់ឡោះស្រលាញ់អ្នកធ្វើកុសលទាន ។

- អល់ឡោះមានបន្ទូលនៅក្នុងជំពូកអាន់នីសាក វាក្យខ័ណ្ឌទី២៩ថា:

(ولا تقتلوا أنفسكم إن الله كان بكم رحيما) النساء:២៩

មានន័យថា: ពួកអ្នកកុំសំលាប់ខ្លួនឯងអោយសោះ ព្រោះអល់ឡោះមានក្តីមេត្តាបំផុតដល់ពួកអ្នក ។

ភស្តុតាងទាំងនេះនិងភស្តុតាងដទៃទៀតបង្ហាញថា: អល់ឡោះបានហាមឃាត់រាល់អ្វីៗដែលមិនល្អ ឬក៏នាំអោយមានគ្រោះថ្នាក់ ពីព្រោះថាអ្វីៗដែលមិនល្អ ឬនាំអោយមានគ្រោះថ្នាក់ គឺច្បាប់មិនអនុញ្ញាតអោយឡើយ របស់ទាំងនេះគេស្គាល់វាតាមស្លាកស្នាម នៃផលប៉ះពាល់របស់វាពីការបង្កអោយមានផលលំបាក ។ បារីសារធាតុអាក្រក់បំផុតនិងបង្កនូវគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដែលមនុស្សគ្រប់ៗគ្នាបានដឹងយ៉ាងច្បាស់ ហើយអ្នកប្រើប្រាស់វានោះគឺជាអ្នកដែលយល់ដឹងច្បាស់ជាងអ្នកដទៃ តែឆន្ទៈរបស់ពួកគេទន់ខ្សោយពេកធ្វើអោយសេចក្តីភ្លើតភ្លើនអាចគ្របដណ្តប់បាន ទោះបីគេដឹងពីភាពអន្តរាយ របស់វាហើយក៏ដោយ ។ សាសនវិទូជាច្រើនបានកំណត់ថា:



ច្បាប់ហាមឃាត់ចំពោះចំណីអាហារ និងភេសជ្ជៈទាំងឡាយណាដែលវានាំអោយគ្រោះថ្នាក់ ។ ការបំផ្លាញ និងការប៉ះពាល់ផ្នែកសាសនាដែរនោះគឺពិតណាស់មានភាពធ្ងន់បំផុតចំពោះខ្ញុំរបស់ទ្រង់ក្នុងការគោរពប្រតិបត្តិ និងបំពេញរាល់ការបង្គាប់ប្រើរបស់ទ្រង់ ជាពិសេសការកាន់អំណត់បួសវាធ្វើអោយខ្ញុំបំរើរបស់ទ្រង់ មិនចូលចិត្តអំពើល្អ នេះដោយសារតែវាជាអំពើអាក្រក់ ។ ទាំងនេះ គឺជាចំនុចអវិជ្ជមានមួយយ៉ាងចំបងដែលធ្វើអោយមនុស្សស្ថិតក្នុងអំពើអបាយមុខ ឃ្លាតឆ្ងាយពីជំរើស ដែលជាហេតុនាំអោយក្លាយជាសត្រូវនឹងអ្នកធ្វើអំពើល្អ ស្អប់ខ្ពើមចំពោះពួកគេ និងបន្ទុះបង្អាប់ដល់ពួកគេយ៉ាងខ្លាំងដៃ ។បើការប្រព្រឹត្តនេះមានតាំងពីក្មេងឬពេលពេញវ័យច្បាស់ជាគេត្រូវជួបបញ្ហាយ៉ាងធំធ្លាក់ខ្លួនចូលក្នុងជ្រោះមហន្តរាយពុំខាន ដែលជះឥទ្ធិពលដល់ការបាត់បង់សុជីវធម៌និងក្រមសីលធម៌របស់ពួកគេវាជាផ្លូវមួយអាក្រក់បំផុត ។

**២- ការបំផ្លាញរាងកាយ:**

ការបំផ្លាញរាងកាយ គឺមានគ្រោះថ្នាក់ធំបំផុត ដូចជា: ធ្វើអោយខ្សោយកំលាំង ខ្សោយភ្នែក វារាលដាលនិងបំផ្លាញដល់រាង្គកាយ និងសរសៃឈាមនាំដល់ការស្រុតកំលាំង បណ្តាលអោយគ្រប់សរីរាង្គទាំងអស់មិនទទួលបានផលពីការបរិភោគអាហារ ។ ពេលណាចំនុចគ្រោះថ្នាក់ទាំងពីរ នេះវារួមគ្នាវានឹងបង្កគ្រោះថ្នាក់បំផុត ដូចជា : ខ្សោយបេះដូង ប៉ះពាល់សសៃប្រសាទនិងមិនឃ្លានអាហារ ។ ផលប៉ះពាល់របស់វាផងដែរគឺ: ក្អក រលាកច្រមុះនិងបំពង់កយ៉ាងខ្លាំង ដែលនាំអោយស្ទះដង្ហើម ហើយពិបាកដកដង្ហើម ។

ការស្លាប់ និងក្តីអន្តរាយមានច្រើនណាស់មកហើយក្នុងបញ្ហានេះ!។ មានវេជ្ជបណ្ឌិតជាច្រើនបានបញ្ជាក់ថា: ការជក់បារីបានបន្សល់នូវស្លាកស្នាមយ៉ាងធ្ងន់ធ្ងរនៃជំងឺក្នុងទ្រូង ជាមូលហេតុដែលនាំអោយមានជំងឺមហារីកដែលនេះគឺជាជំងឺដ៏សាហាវបំផុត ។

រឿងដែលចំឡែកបំផុតសំរាប់អ្នកមានសតិបញ្ញាញាណ គឺគេយកចិត្តទុកដាក់ចំពោះសុខភាពរបស់គេ តែគេនៅតែជក់បារីដដែលបើទោះបីគេបានឃើញពីផលប៉ះពាល់របស់វាហើយក្តី ។ តើមានមនុស្សប៉ុន្មាននាក់ហើយដែលអន្តរាយដោយការធ្វេសប្រហែស និងមើលស្រាលទៅលើជំងឺនោះ!។ វាក៏ជារឿងហួសចិត្តផងដែរត្រង់ថា:មនុស្សមួយចំនួនគេមិនស្តាប់ការណែនាំ និងចង្អុលបង្ហាញរបស់លោកវេជ្ជបណ្ឌិតក្នុងបញ្ហានេះឡើយ ហេតុអ្វីបានជាពួកគេព្រងើយកន្តើយចំពោះកិច្ចការដ៏សែនគ្រោះថ្នាក់នេះ! នេះក៏ដោយសារសេចក្តីភ្លើតភ្លើនវាមានអំណាចគ្រប់គតិបណ្ឌិតរបស់មនុស្សលាយឡំនឹងភាពទន់ខ្សោយក្នុងការពង្រឹងគោលជំហរផង និងយកទំលាប់មកធ្វើបំពានទៅលើផលប៉ះពាល់ ។ ក៏នៅមានគ្រោះថ្នាក់មួយចំនួនទៀតដែលយើងបានលើកមកបង្ហាញ គឺវាធ្វើអោយមាត់ បបូរមាត់ និងធ្មេញឡើងខ្មៅ និងនាំដល់ការលំបាកក្នុងការទទួលទានអាហារ ជាពិសេសគឺការឈឺចាប់នូវអ្វីដែលមិនគួរឈឺ ។ ក្នុងចំណោមជំងឺជាច្រើន គឺមានជំងឺហើមផងដែរដែលកើតឡើងពីការជក់បារីនោះ! បុគ្គលណាតាមសង្កេតក្នុងរឿងនេះ គេនឹងជួបរឿងច្រើនជាងអ្វីដែលយើងបានលើកយកមកបញ្ជាក់ប្រាប់ទៅទៀត ។



មហារីកសួត សួតធម្មតា

*សារធាតុពុលក្នុងបារីធ្វើឲ្យ*
*+ ក្រិនសាច់សួត*
*+ មហារីកសួត*






កូនថង់សួតរលាក

កូនថង់សួតធម្មតា

បារីធ្វើឲ្យពុកធ្មេញ និងខូចអញ្ចាញធ្មេញ



### ទងសួតធម្មតា

### ទងសួតរលាក





*សារធាតុពុលក្នុងបារីធ្វើឲ្យ*

*+ ថយចុះប្រព័ន្ធការពារក្នុងសួត*

*+ រលាកទងសួតរ៉ាំរ៉ៃ*

*+ ធ្វើឲ្យក្អក និងហាត់រាំរ៉ៃ*

### ការហូរឈាមក្នុងក្រពះ

### ដំបៅក្រពះ





*សារធាតុពុលក្នុងបារីធ្វើឲ្យ*

*+ រលាក និងដំបៅក្រពះរ៉ាំរ៉ៃ ដែលអាចវិវត្តិទៅជាមហារីកក្រពះ*

*+ ហូរឈាមក្នុងក្រពះ*



### ដុំសាច់មហារីកក្នុងខួរក្បាល



*សារធាតុពុលក្នុងបារីធ្វើឲ្យ*

*+ មហារីកខួរក្បាល*

*+ ដាច់ ឬស្ទះសរសៃឈាមខួរក្បាល ដែលធ្វើឲ្យស្លាប់ភ្លាមៗ ឬស្លាប់មួយចំហៀងខ្លួន*

## ៣- ការប៉ះពាល់របស់វាទៅលើទ្រព្យសម្បត្តិ:

ចំណែកឯការបំផ្លាញនិងផលប៉ះពាល់របស់វាដល់ទ្រព្យសម្បត្តិនោះគឺដូចដែលបានបញ្ជាក់យ៉ាងច្បាស់ពីណាហ្គី ក្នុងការហាមឃាត់ពីការបំផ្លាញទ្រព្យសម្បត្តិ ហើយដែលការបំផ្លាញដល់ក៏រិតនោះគឺការជក់បារីនេះឯងដែលមិនធ្វើអោយរាង្គកាយធំធាត់មិនអាចបំបាត់ការស្រេកឃ្លាន មិនផ្តល់សារៈប្រយោជន៏អ្វីសោះឡើយ រហូតដល់អ្នកងុបងល់នឹងវាកំពុងបំផ្លាញទ្រព្យសម្បត្តិយ៉ាងច្រើនឈានដល់ការជំពាក់បំណុលគេអាចថាបាន គេបោះបង់ភារកិច្ចផ្គត់ផ្គង់ចាំបាច់ផងដែរ ដែលនេះគឺជាការបំពានមួយយ៉ាងធំបំផុត។ វាបំផ្លាញរាង្គកាយ ចំណាយលុយកាក់ឥតប្រយោជន៏ទៅលើវា ចុះហេតុអ្វី

បានជាគេនៅតែបន្តចំណាយទៅលើអ្វីដែលគេបានដឹង ពីការគ្រោះថ្នាក់របស់វាហើយនោះ!!!

បើបារីវាមានផលប៉ះពាល់ដល់សាសនា ដល់រាង្គកាយ និងទ្រព្យសម្បត្តិ គឺការជួញដូរវា ក៏ត្រូវបានច្បាប់អ៊ីស្លាមហាមឃាត់ដែរ ។ មនុស្សដែលមិនបានដឹងអំពីច្បាប់ គេពិតជាយកបង្អែកទៅតាមសាសនវិទូ ដូចនេះសាសនវិទូមិនត្រូវបណ្តោយអោយមនុស្សប្រភេទនេះ ដើរតាមចំណង់របស់ពួកគេឡើយ ហើយពួកគេមិនត្រូវគិតថា មានអ្នកថាការជក់បារីមិនត្រូវបានច្បាប់ហាមឃាត់ដែរ ព្រោះការយល់ឃើញរបស់អ្នកមិនបានដឹងពីច្បាប់ វាមិនមែនជាទស្សនៈឯកភាពគ្នារបស់សាសនវិទូអ៊ីស្លាមនោះឡើយ ដោយសារពួកគេមិនអាចចេញផុតពីសំដីរបស់សាសនវិទូរបស់គេ តាមបន្ទូលរបស់អល់ឡោះនៅក្នុងជំពូកអាន់ណះលី វាក្យខ័ណ្ឌទី៤៣ថា:

**(فَاسأَلُوا أَهلَ الذكْرِ إِنْ كُنتم لاَ تعلَمونَ) النحل :** ៤៣

មានន័យថា : **ចូរពួកអ្នកសួរអ្នកចេះដឹងប្រសិនបើពួកអ្នក មិនដឹងទេនោះ ។**

ការបកស្រាយខុសធ្វើអោយមានផលប៉ះពាល់ដល់អ្នកមិនដឹងច្បាប់ដើរតាមចំណង់របស់ខ្លួនមិនអាចងាកមករកការពិតនិងការចង្អុលបង្ហាញបានទេ។ ឧទាហរណ៏ដូចអ្វីដែលពួកគេតែងនិយាយថា: មានសាសនវិទូមួយចំនួនយល់ថា:មិនចាំបាច់អោយមានលំនឹងនៅក្នុងសឡាហ៏ឡើយ ។ សាសនវិទូទាំងនោះមិនជំទាស់នឹងយើងឡើយ បើពួកយើងព្រមអនុវត្តតាមពួកគាត់នោះឬក៏ថា: មានអ្នកដែលកាត់ថា: ចងការគឺអាចប្រើបាន ហើយពួកយើង



ត្រូវតែដើរតាមទស្សនៈនេះ ។ បើសិនជាច្រកនេះត្រូវគេយកមកអនុវត្តនោះច្បាស់ជាធ្វើអោយមនុស្សជួបនូវអំពើអាក្រក់ និងអាចក្លាយទៅជាមូលហេតុដែលធ្វើអោយអ្នកមិនដឹងពីច្បាប់បំផ្លាញខ្លួនគេមិនខានឡើយ បើដូចដែលគេធ្វើតាមទស្សនៈខុសឆ្គងដែលគ្មានភស្តុតាងមកបញ្ជាក់បង្ហាញទាំងនេះក្នុងចំណោមប្រការដែលច្បាប់មិនអនុញ្ញាតនោះ ។ ការកំណត់ច្បាប់ពិតប្រាកដនោះគឺតាមរយៈភស្តុតាង និងរូបមន្តគោលនៃច្បាប់ ហើយបញ្ហាបារីត្រូវហាមឃាត់ព្រោះវាជាក្តីវិនាសអន្តរាយគ្រប់យ៉ាង ។តាមរូបមន្តគោលនៃច្បាប់គឺរាល់ប្រការដែលបង្កអោយមានគ្រោះថ្នាក់ដល់មនុស្ស ទាំងផ្នែកសាសនា ទាំងរាងកាយ និងទ្រព្យសម្បត្តិ ដោយគ្មានផ្តល់ផលប្រយោជន៏អ្វីនោះវាពិត ជាត្រូវបានច្បាប់ហាមឃាត់ ។ ចុះទំរាំបារីវាមានផលប៉ះច្រើនយ៉ាងដល់មនុស្សតើវាយ៉ាងណាទៅវិញ!!!

ដូចនេះចាំបាច់លើបុគ្គលដែលចង់កែប្រែខ្លួន ហើយដែលរូបគេជាមនុស្សម្នាក់ជាគំរូនិងជាអ្នកដែលសង្គមទទួលស្គាល់ គឺគេត្រូវសារភាពកំហុសចំពោះអល់ឡោះឈប់ជក់បារី ត្រូវតាំងចិត្តអោយបាន ដោយសុំពីអល់ឡោះអោយជំរុញចិត្តបញ្ចៀសឆ្ងាយពីវានិងមិនត្រូវទន់ជ្រាយឡើយ គេត្រូវដឹងថាជនណាបានលះបង់ទង្វើអាក្រក់ណាមួយ ដើម្បីបុព្វហេតុអល់ឡោះជាម្ចាស់អល់ឡោះនឹងជំនួសអោយគេវិញនូវអំពើល្អប្រសើរពេលនោះគឺវាងាយបំផុតសំរាប់រូបគេក្នុងការលះបង់ ។ ដូចគ្នានេះដែរផលនៃការបោះបង់អំពើអាក្រក់នោះ នៅពេលដែលកិច្ចការដែលមានផលលំបាកនោះវាពិតជាមានកុសល

និងផលបុណ្យដ៏ប្រពៃបំផុត។ បុគ្គលណាដែលអល់ឡោះយល់ព្រមដល់រូបគេ និងការពារគេអោយបានបោះបង់បាវីនោះ ពិតណាស់រូបគេបានជួបនូវផលលំបាកពីចំនុចដំបូងក្រោយមកវានឹងរំសាយម្តងបន្តិចៗ រហូតដល់អល់ឡោះបានបំពេញឧបការៈគុណដល់គេ។ អល់ឡោះនឹងផ្តល់ភាពរីករាយដោយឧត្តមភាពរបស់ទ្រង់ចំពោះរូបគេ ការថែរក្សារបស់ទ្រង់ការការពាររបស់ទ្រង់ដល់រូបគេ។ រូបគេត្រូវណែនាំដល់បងប្អូនរបស់គេនូវអ្វីដែលរូបគេបានណែនាំសំរាប់ខ្លួនរបស់គេ។ រាល់ការចង្អុលបង្ហាញទាំងអស់នៅក្នុងដៃរបស់អល់ឡោះ។ បុគ្គលណាហើយដែលបានលះបង់អ្វីមួយដើម្បី អល់ឡោះជាម្ចាស់ទ្រង់នឹងតបស្នងអោយគេវិញនូវរបស់ដែលគេបានលះបង់។ ត្រូវដឹងថាផលបុណ្យសំរាប់កិច្ចការលំបាកច្រើនជាងផលបុណ្យនៃកិច្ចការស្រាល ហើយផលបុណ្យរបស់អ្នកលះបង់ទង្វើអបាយមុខណា ដែលវាមានលក្ខណៈធ្ងន់ធ្ងរនោះក៏ទំហំនៃកុសលវាទៅតាមនោះដែរ។ បុគ្គលណាហើយដែលអល់ឡោះប្រទានអោយគេ នូវការភ្ញាក់រលឹកនឹងជួយ គេចំពោះការលះបង់ការជក់បារីគឺគេជួបនូវការលំបាកខ្លាំងក្នុងជំហានដំបូងមែន តែបន្តបន្ទាប់មកគេនឹងបានធូរស្រាលឡើងៗ រហូតដល់អល់ឡោះបំពេញសាធុការរបស់ទ្រង់ដល់រូបគេហើយរូបគេនឹងរីករាយពីពរជ័យរបស់ទ្រង់ពីការថែរក្សារបស់ទ្រង់ចំពោះរូបគេ និងពីការជួយរបស់ទ្រង់មកលើរូបគេ។ បុគ្គលនោះត្រូវចេះ អប់រំខ្លួនឯងបន្ទាប់មកអប់រំដល់អ្នកផងទាំងពួងផង ព្រោះការសំរេចផលស្ថិតនៅលើអល់ឡោះជាម្ចាស់។ បុគ្គលណាហើយដែលអល់ឡោះដឹងពីចិត្តស្មោះត្រង់



របស់គេក្នុងការសុំទ្រង់អោយជួយគេចំពោះទង្វើណា ដែលទ្រង់បង្គាប់ប្រើ និងសុំពីទ្រង់អោយជួយដល់ការលះបង់ពីទង្វើអបាយមុខគឺទ្រង់នឹងជួយសំរួលដល់រូបគេពុំខានហើយទ្រង់នឹងបញ្ចៀសរូបគេពីការលំបាក។ ទ្រង់ពិតជាសំរួលអោយគេនូវរាល់ប្រការល្អមិនខានឡើយ។

សុំបួងសួងពីអល់ឡោះម្ចាស់ សូមទ្រង់អោយការក្រើនរំលឹករបស់យើងខ្ញុំនេះនាំដល់កុសលផលបុណ្យផងចុះ ហើយសូមទ្រង់រក្សាពួកយើងខ្ញុំពីទង្វើអបាយមុខផ្សេងៗផង ទ្រង់ហើយដែលមានចិត្តសាធារ និងពោរពេញទៅដោយក្តីករុណាអាណិតស្រលាញ់បំផុត។

ربنا آتنا في الدنيا حسنة وفي الآخرة حسنة وقنا عذاب النار،وصلى الله على نبينامحمد وعلى آله وأصحابه أجمعين.